# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

ទំព័រ

### ផ្នែកអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ ..... ព្រះរាជប្រវត្តិសម្ដេចព្រះរាជអយ្យកោ នរោត្តម-សុធារស ......... ៥៣

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម.... រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១រូបឈ្មោះ ហ្វូន-ឆាង ស្រង់ប្រែពីសៀវភៅ Religieux et pèlerins en terre d'Asie (តមក) ....... ៦៨

យុនបញ្ញាសោភ័ន គាំ-ឌុម ... ពតិមាន ថ្លែងសេចក្ដីកាលទៅនាំយកព្រះពុទ្ធរូបនិងបល្ល័ង្ក នៅអង្គរបូរី ស្រុកព្រៃកប្បាស (តាកែវ) (តមក) ...... ៧៩

ព្រះគ្រូមុនីសោភ័ន សោម-ឡុច គាថាភាសិត (តមកនិងចប់) ...... ៩៤

### ផ្នែកសាសនា

យុនបណ្ណានុរក្ស ប៊ូ-ប៊ូ ..... ប្រវត្តិព្រះពុទ្ធ ៣ ព្រះអង្គ ........ ១០០

លោកគ្រូអាចារ្យ ប៉ាង-ខាត់.... អរិយសច្ច ជាពុទ្ធភាសិត (តមក) .... ១០៤

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhiqu
Rédacteur en chef de la partie littéraire : Luong Nibandhamantr NHOK-THÊM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Preah kru Paññalikhit KAO-SIM, Surveillant général de l'École Supérieure de Pāli.


## *TABLE DES MATIÈRES*

**Partie littéraire**:


| | | Pag |
|---|---|---|
| Institut Bouddhique . . | Biographie de S. A. R. le Sămdech Prĕah Reach ayyakò Norodom Sottharoth . . . . . . . . . . | 57 |
| Luong Nīponmontrei Nhok-Thêm. . . . . . | Récit du pèlerin chinois Hiuen-tsang ( extrait de *Religieux et Pèlerins en Terre d'Asie)*(suite) | 68 |
| K'ŭn Panhnha sòp'ĕan Kam-Doum . . . . . | Rapport sur le transfert des statues de Bouddha d'Angkorborei (Takév) à Phnôm-Penh (suite) | 79 |
| Prĕah kru mŭnisòp'ĕan Sòm-Loch. . . . . . | Neaneap'casăt (suite et fin). . . . | 94 |


**Partie religieuse**:


| | | |
|---|---|---|
| K'un Pannanŭrak Bou Po | Biographie des sept Bouddhas passés . . . . . . . . . . . . | 100 |
| Vén. Achar Pāng-Khat. . . | Ariyasaccā - Buddhabhāsitā (suite) | 104 |



17e Année — N° 2. Février 1945 — Abonnement: un an 15$00.

# ព្រះរាជប្រវត្តិ

## សម្តេចព្រះរាជអយ្យកោ វរក្សត្រណារិទ្ធ នរោត្តម-សុត្ថារស

ក្រុមជំនុំ ដំឡើងលេខាប្រជុំធម្មវណ្ណារ ក្រុងពាំងសស
មហាសិរីវឌ្ឍ ក្រុងកម្ពុជាធិបតី

សម្តេចព្រះរាជអយ្យកោ ព្រះអង្គនេះ ជាព្រះរាជបុត្រព្រះបាទសម្តេចព្រះនរោត្តមបរមរាមទេវាវតារ ព្រះចៅក្រុងកម្ពុជាធិបតីនឹងចៅចមមាគាត់រៀម-បុស្បា ។ ទ្រង់ព្រះប្រសូតនៅថ្ងៃសុក្រមួយកើតខែអស្សុជ ឆ្នាំរកចត្វាស័ក ពុទ្ធសករាជ ២៤១៩ ត្រូវគ្នានឹងថ្ងៃ ១៨ ឧកតូប្រ៍ ឆ្នាំ ១៨៧៦ វេលាម៉ោង ១ ជាធអធ្រាត្រ នៅក្នុងព្រះបរមរាជវាំង ចតុមុខ ក្រុងភ្នំពេញនេះ ។

សម្តេចព្រះវររាជបិតា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រោសឲ្យធ្វើព្រះរាជពិធីចំរើនព្រះកេសាកំណើត នៅថ្ងៃ ៨កើតខែមិគសិរ ក្នុងឆ្នាំនោះឯង មានព្រះនាមក្នុងព្រះសុវណ្ណបដ ហារិកទន្លែងមាសថា "ព្រះរាជបុត្រាព្រះអង្គម្ចាស់ សុត្ថារស" ។ លុះព្រះជន្មបាន ៦ វស្សា ព្រះបាទសម្តេចជាអម្ចាស់ជីវិតលើត្បូងព្រះវររាជបិតា ត្រាស់ឲ្យហៅចៅឃុនព្រះបរមស្រីកញ្ញាដែលជាបាទបរិចារិកា ព្រះបាទសម្តេចព្រះករុណា ព្រះបរមរាជឲ្យទទួលព្រះអង្គមកបីបាច់រក្សា ទ្រង់ស្តេចមកគង់នឹងចៅឃុនព្រះបរមស្រីកញ្ញា នៅវាំងកែវព្រះភ្លើង នៅថ្ងៃ ១ កើតខែបុស្ស ឆ្នាំជូវទោស័ក ព.ស. ២៤២០ ចៅឃុនបានឲ្យទ្រង់រៀន

អក្សរខ្មែរ ព្រះជន្មបាន ៩ វស្សា ទ្រង់ចេះអក្សរភាសាបារាំងសេសកើតល្មមប្រើការបាន ។ លុះព្រះជន្មបាន ១១ ព្រះវស្សា មានព្រះរាជពិធីសោកន្តនៅថ្ងៃ ១៥ កើតខែផល្គុន ឆ្នាំមមីចត្វាស័ក ព.ស. ២៤២៥ ។

កាលព្រះជន្មបាន ១៦ ព្រះវស្សា ព្រះបាទសម្តេចអម្ចាស់ជីវិតលើត្បូង ជាព្រះវររាជបិតា ត្រាស់ប្រើឲ្យទ្រង់ព្រាយលាជ ក្នុងក្បួនហែព្រះសពសម្តេចព្រះអនុជភាព ជាព្រះរាជមាតាសម្តេចម្ចាស់ហ្យា-បទុមអក្ត ។

កាលព្រះជន្មបាន ១៣ ព្រះវស្សា ទ្រង់បានចូលទៅថ្វាយព្រះអង្គជាសិស្សសម្តេចព្រះសុគន្ធាធិបតី "ប៉ាន" ជាសង្ឃនាយកគណៈធម្មយុត្តិ មានសម្តេចព្រះមង្គលទេពាចារ្យ អៀម កាលនៅជាព្រះគ្រូ ជាអ្នកបង្ហាត់បង្រៀនពុទ្ធសាសនធម៌ និងស្យាមអក្សរ ។

កាលព្រះជន្មបាន ១៥ ព្រះវស្សា មានព្រះរាជពិធីខ្វន់នាគបព្វជ្ជា ទ្រង់ព្រះផ្នួសជាសាមណេរ នៅថ្ងៃ ១៥ កើតខែអាសាឍ ឆ្នាំចអដ្ឋស័ក ព.ស. ២៤២៩ បានទ្រង់រៀនព្រះត្រៃបិដកនឹងសម្តេចព្រះសុគន្ធាធិបតី ជាឧបជ្ឈាចារ្យ ទ្រង់ព្រះផ្នួសគង់នៅវត្តបទុមវតីរាជវរារាម បាន ១ ព្រះវស្សា ទ្រង់លាចាកសិក្ខាបទនៅខែបុស្សឆ្នាំនោះ ។

កាលទ្រង់លាចាកព្រះផ្នួសមក ព្រះករុណាមានព្រះរាជឱង្ការត្រាស់ឲ្យទ្រង់សិក្សាសិល្បវិជ្ជាក្នុងក្រុមកងទាហានសេះ ហើយទ្រង់

បានតាមហែស្ដេចព្រះរាជដំណើរទៅស្រុកព្រៃនគរដោយវិថីជលមាគ៌ ជាច្រើនដង ។

លុះព្រះជន្មបាន ២១ ព្រះវស្សា ទានព្រះរាជពិធីទូលខ្ញាតបួស-ម្នាងជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនា ក្នុងព្រះវិហារវត្តបទុមវតីរាជវរារាម មានសម្ដេចព្រះសុគន្ធាធិបតីជាព្រះឧបជ្ឈាយ៍ មានសម្ដេចព្រះមង្គល-ទេពាចារ្យ អៀម (កាលនៅជាព្រះរាជាគណៈ) ជាកម្មវាចា ទ្រង់ព្រះផ្នួស នៅថ្ងៃ ១៤ កើតខែអាសាឍ ឆ្នាំថោះត្រីស័ក ព.ស. ២៤៣៥ ។ ទ្រង់សិក្សាធម្មវិន័យបាន២ វស្សា ទ្រង់លាចាកសិក្ខានៅថ្ងៃ១០ កើត ខែកត្ដិក ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៦ ។

លុះព្រះជន្មបាន ២៣ ព្រះវស្សា ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាព្រះវររាជបិតា ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទីកសិទ្ធិរក្សា-ហមង្គលមឹងព្រះអង្គម្ចាស់ម៉ាំ ព្រះរាជបុត្រី ហើយជាព្រះរាជបុត្រីពៅនៃចៅពញាមាតាស៊ុជាតបុប្ផា ព្រះស្នំឯក ជាព្រះជាយា នៅខែអាសាឍឆ្នាំមមីឆស័ក ព.ស. ២៤៣៧ ត្រូវនឹងឆ្នាំ ១៨៩៥ ។

កាលនៅថ្ងៃ ១៣ ហ្វេវ្រីយេ ឆ្នាំ ១៨៩៧ បានទ្រង់ព្រះករុណាប្រោសព្រះរាជទានគ្រឿងឥស្សរិយយសឈ្មោះអូប៉ស៊ីយេ ឌឺម៉េ-ដៃយមាសនៃក្រុងកម្ពុជា ។ ក្នុងរដ្ឋកាលនោះ បានត្រាស់ប្រើឲ្យថ្វាយទៀនព្រះវស្សា ផ្កាពុម្ព ខ្ញុំព្រះកឋិនតាមព្រះអារាមហ្លួងរាល់ឆ្នាំ ។

លុះមកដល់ថ្ងៃអាទិត្យ ១០ កើតខែពិសាខឆ្នាំរោងឆស័ក ព.ស. ២៤៤៧ វេលាម៉ោង ១៧ និង ៥ មិនុត ត្រូវនឹងថ្ងៃ ២៤ ខែអាព្រិល ឆ្នាំ ១៩០៤ ។ ព្រះបាទសម្តេចអម្ចាស់ជីវិតលើត្បូង ជាព្រះវររាជបិតា ទ្រង់សោយព្រះទិវង្គត ដោយព្រះរោគជរាភាព ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ឡើងគ្រងរាជសម្បត្តិស្នងព្រះបរមរាជាធិរាជ បានទ្រង់កប់កាន ព្រះអង្គតាមទំនៀមព្រះបរមរាជវង្សានុវង្ស ។

កាលនៅថ្ងៃ ៤ ខែណូវ៉ែម្ប្រ៍ ឆ្នាំ ១៩០៤ មានការកើតលោកឡឺរេស៊ីដង់ស៊ុបេរីយ៉េរ តាំងព្រះអង្គជាក្រុមកុម៉ីស្យុងពិនិត្យនាទីដី ក្នុងក្រុងភ្នំពេញ មានម៉ុងស៊ីយ៉េហោន រេស៊ីដង់មែរជាប្រេស៊ីដង់ ។

កាលនៅថ្ងៃ២៤ដេសម្ប្រ៍ឆ្នាំ១៩០៤ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់គ្រងរាជសម្បត្តិថ្មី បានត្រាស់ប្រើព្រះអង្គជាព្រះរាជអាជ្ញាទៅស្រុកក្រាត ជាមួយនឹងម៉ុងស៊ីយ៉េរម៉ូរ៉េល រេស៊ីដង់ស៊ុបេរីយ៉េរ ទៅទទួលខែត្រដែនអំពីរាជការសៀម មកជាឧបខណ្ឌ សីមានៃក្រុងកម្ពុជាធិបតី ក្នុងខណៈនោះ បានទ្រង់ព្រះករុណាប្រោស ព្រះរាជទានគ្រឿងឥស្សរិយយសឈ្មោះក្រង់អូហ្វីស៊ីយេរ របស់ក្រុងកម្ពុជា ។

កាលនៅថ្ងៃ១ ខែមេឆ្នាំ ១៩០៥ មានការកើតរាជការប្រតិកត្តូរ៉ាត់ តាំងឲ្យទ្រង់ធ្វើក្រុមកុម្ម៉ីស្យុង ជំនុំអំពីសេចក្តីដែលនឹងបង្កើតសាលា

រៀន បង្រៀនវិជ្ជាផ្សេងៗ ឲ្យចំរើនក្នុងក្រុងកម្ពុជា មានដុកទ័រខ្មែរ ជាប្រេស៊ីដង់ ។

កាលនៅថ្ងៃ៣ខែសេប្តេម្ពឆ្នាំ ១៩០៥ មានអារ៉េតតាំងឲ្យទ្រង់ ធ្វើជាក្រុមកុម្ម៉ង់ស្យុងតែងច្បាប់ខ្មែរ មានម៉ុងស៊ីយើរ៉េស្ប៊ូ អ៊ដមីនស្ត្រាទ័រ ជាប្រេស៊ីដង់ ។

កាលនៅថ្ងៃ ២៧ ខែអាវ្រីលឆ្នាំ ១៩០៦ ប្រតិកគូពីក៍បានថ្វាយ គ្រឿងឥស្សរិយយស ឈ្មោះអូហ្វីស៊ីយេរ ត្រាកុងដ័ណ្ណាម ។ ព្រះបាទ សម្តេចព្រះស៊ីសុវត្ថិព្រះចៅក្រុងកម្ពុជា បានទ្រង់ព្រះរាជទានគ្រឿង ឥស្សរិយយសឈ្មោះមុនីសុកករណ: ។

កាលនៅថ្ងៃ ៧ ខែមេឆ្នាំ ១៩០៦ មានអារ៉េតអំពីប្រតិកគូពីក តាំង ឲ្យទ្រង់ធ្វើជាប្រេស៊ីដង់ ដឺ:ដេលេគេនៃក្រុងកម្ពុជា ស្តេចទៅបុណ្យ អិកស្ប៉ូស៊ីយុង ស្រុកម៉ាសៃប្រទេសបារាំងសែស ហើយបានស្តេច យាងទៅក្រុងប៉ារីសផង ។ ខណៈដែលស្តេចទៅដល់ ទ្រង់បានទទួល គ្រឿងឥស្សរិយយសឈ្មោះម៉េដៃយសិរីសុវត្ថិ អំពីព្រះចៅក្រុងកម្ពុជា-ធិបតី បានទទួលគ្រឿងឥស្សរិយយសអំពីរដ្ឋបាលបារាំងសែស ឈ្មោះ អូហ្វីស៊ីយេរម៉េរិតអាគ្រីកុល ១ ម៉េដៃយកុម្មេម្មូរ៉ាទីវ ១ ទ្រង់គង់នៅក្រុង បារាំងសែស ៤០ ថ្ងៃ ស្តេចវិលមកក្រុងកម្ពុជាវិញ ។

ទ្រង់បានបង្កើតការរៀនកុមារ ១ ធ្វើទៅខាងដេរដែកកាំងដែលទ្រង់គង់ កេនរៀននេះម៉ុងស៊ីយេរ៍អ៊ូត្រេស៊ីជងក៏ស៊ុយេរ៉ៃយេរ៍ ទីនម៉ុងស៊ីយេរ៍កូឡា រេស៊ីជងតមែរ ទីនម៉ុងស៊ីយេរ៍ម៉ូលីយេរ អាំងស្ប៉ិកទ័រក្រុងយកចិត្តឈឺឆ្អាលជួយឧបត្ថម្ភដោយក្រៃពេក កាលនៅវេលាដែលធ្វើងកេនរៀននោះសោត មានម៉ុងស៊ីយេរ៍សាខូ គូវេរណ៍រហ្សេណាក់ល់ទីនម៉ុងស៊ីយេរ៍អ៊ូត្រេស៊ីជងក៏ស៊ុយេរ៉ៃយេរ៍ជាប្រធាន ខូរសេនាបតីមន្ត្រីបារាំង-ខ្មែរទាំងឡាយបានប្រជុំសន្និបាត ម៉ុងស៊ីយេរ៍ឡឺគូវេរណ៍រហ្សេណាក់ល់ បានថ្លែងសុន្ទរកថានៈជាអនេកប្រការ ។

កាលនៅថ្ងៃ ១២ ខែស៊ីយោគឆ្នាំ ១៩១៦ ទ្រង់បានះស្តេចទៅស្រុកព្រៃនគរដោយថ្វីកជការ ទៅទទួលគ្រឿងឥស្សរិយយសៈ ឈ្មោះស៊ីកលីយេរដឺឡាលេស្យុងដូណើរ អំពីលោកឡឺគូវេរណ៍រហ្សេណាក់ល់ ហើយទ្រង់បានគុម្ពន្ទ័រ ប្រទេសជប៉ុនផង ។

កាលឆ្នាំ ១៩១៦ ទ្រង់បានស្តេចទៅទទួលធំ ៣ ដើង ក្នុងកិច្ចពជការរើសមនុស្ស ដែលស្ម័គ្រចិត្តទៅជួយក្នុងការសង្គ្រាមប្រទេសបារាំងសែស បានមនុស្សជាង ៤០០ នាក់ ។

កាលឆ្នាំ ១៩១៧ ទ្រង់បានទទួលគ្រឿងឥស្សរិយយស ឈ្មោះអូហ្វីស៊ីយេរដឺឡាលេស្យុងដូណើរ ក្រុងបារាំងសែសគមកទៀត ទ្រង់បានធ្វើជាក្រុមជំនុំក្នុងព្រះរាជបណ្ណាល័យ ហើយរដ្ឋបាលបានតាំងឲ្យ

ទ្រង់ធ្វើជាក្រុមជំនុំឲ្យជនានុជនដែលមានចំណេះវិជ្ជាធ្វើគ្រឿងៗ នាំគ្នានោះមកប្រឡងតាំងតាមកាល ។

លុះមកដល់ឆ្នាំថោះនពស័ក ព.ស. ២៤៧០ ត្រូវនឹង គ.ស. ១៩០៧ ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់សោយព្រះទិវង្គត សម្ដេចព្រះកែវហ្វ៉ាមុនីវង្សជាព្រះរាជបុត្រច្បងគ្រងរាជសម្បត្តិស្នងព្រះរាជបិតាអម្ចាស់ផែនដីៗ ក្នុងនេះ ទ្រង់បានព្រះរាជទានគ្រឿងឥស្សរិយយសឈ្មោះក្រង់ក្លាខៃក្រុងកម្ពុជា ។

កាលនៅថ្ងៃ ៣០ យ៉ាំងវីយេឆ្នាំ ១៩២៨ ទ្រង់បានទទួលគ្រឿងឥស្សរិយយសឈ្មោះ កុម្មង់ឌ័រដឺឡាលេស្យុងដូណ័រអំពីរដ្ឋបាលក្រុងបារាំងសែស ។

លុះមកដល់ថ្ងៃអាទិត្យ ១២ រោចខែស្រាពណ៍ឆ្នាំម្សាញ់ឯកស័ក ព.ស. ២៤៧២ ត្រូវនឹងថ្ងៃ ១ សេបតមប្រ៍ ១៩២៩ មានព្រះរាជប្រកាសឲ្យទ្រង់ឡើងព្រះយសជាសម្ដេចក្រុមព្រះវរចក្រណារិន្ទ អធិបតីក្រុមសង្គហៈព្រះបរមរាជវង្សានុវង្ស ហើយទ្រង់បានកុម្មង់ឌ័រស្រុកហ្លួងព្រះបាង អំពីព្រះចៅស៊ីសុវាងវង្ស ដែលទ្រង់បានផ្ញើមកថ្វាយ ។

លុះមកដល់ថ្ងៃពុធ ៣ កើតខែពិសាខ ព.ស. ២៤៧៣ ត្រូវនឹងថ្ងៃ ៣០ ខែអាព្រីលឆ្នាំ ១៩៣០ មានអាសេគតាំងឲ្យទ្រង់ធ្វើជាអធិបតីពុទ្ធសាសនបណ្ឌិត្យ ។

លុះមកដល់ផ្នែកាលបច្ចុប្បន្ននេះ ទ្រង់បានឡើងព្រះយសយ៉ាងខ្ពង់ខ្ពស់ផុត ជាសម្តេចព្រះរាជអយ្យកោវរចក្រណរិទ្ធ (នរោត្តម-សុរាម្រិត) ព្រះអង្គម្ចាស់ក្សត្រធំ ជាព្រះជាយាបានឡើងព្រះយសដ៏ខ្ពង់ខ្ពស់ ជាសម្តេចព្រះរាជអយ្យិកា ខត្តិយកល្យាណីរាជសុភាគវតី ។

សម្តេចព្រះរាជអយ្យកោនិងសម្តេចព្រះរាជអយ្យិកា ទាំងពីរព្រះអង្គនេះ ទ្រង់មានព្រះឱរសព្រះធិតា ដែលមានព្រះជន្មគង់នៅសព្វថ្ងៃនេះ ២ ព្រះអង្គគឺ:

១) ព្រះអង្គម្ចាស់ក្សត្រាសុរម្រិត ប្រសូតនៅថ្ងៃសៅរ៍ ៨ កើត ខែផល្គុនឆ្នាំមមែសប្តស័ក ព.ស. ២៤៣៨ បានសម្តេចព្រះរាជធីតាកុសុមៈ ជាព្រះរាជបុត្រីព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ជាព្រះជាយា ដែលជាសម្តេចព្រះវររាជមាតា-បិតា នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសព្វថ្ងៃនេះ ។

២) ព្រះអង្គម្ចាស់ក្សត្រីរស្មីសោភ័ណ ប្រសូតនៅថ្ងៃអង្គារ ១២ កើត ខែកត្តិកឆ្នាំកុរឯកស័ក ព.ស. ២៤៤២ ។ សព្វថ្ងៃនេះ បានឡើងព្រះយសជាសម្តេចព្រះបិតុច្ឆារស្មីសោភ័ណ ។

## ព្រះបរិយាសម្បត្តិនិងព្រះគុណសម្បត្តិ

សម្តេចព្រះរាជអយ្យកោនេះ ទ្រង់បានប្រកបករណីយកិច្ចផ្សេងៗ ដែលជាប្រយោជន៍ទាំងខាងផ្លូវអាណាចក្រ និងខាងពុទ្ធចក្រជាច្រើន

ប្រការ ដូចយើងបានពោលពណ៌នាមកខាងលើនេះ ៗ មុនក្រសួងសំខាន់ខាងក្រោយបង្អស់ដែលទ្រង់បានទទួល គឺជាអធិបតីនៃពុទ្ធសាសនបណ្ឌិត្យ តាំងអំពីកាលនោះមក ទ្រង់យកព្រះទ័យឈឺឆ្អាលជួយផ្ទៀងផ្ទាត់ព្រះត្រៃបិដក ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយ ដរាបមកដល់ថ្ងៃទ្រង់ប្រឈួនជាទម្ងន់ ៗ សម្តេចព្រះរាជគណៈព្រះអង្គនេះ ទ្រង់ជាមហាសប្បុរស មានព្រះរាជអធ្យាស្រ័យទន់ភ្លន់គួរជាទីគារព មានព្រះមេត្តាករុណាដល់បណ្តាជនទូទៅមិនរើសមុខ ជាក្សត្រទ្រង់ធម៌ដ៏ហ្មត់ចត់តែងទ្រង់និច្ចសីលនឹងឧបោសថសីលពុំដែលដាច់ ទ្រង់ព្រះសណ្តាប់ធម៌ទេសនារាល់ ៗ ថ្ងៃឧបោសថ ទ្រង់សិក្សានឹងទ្រង់សាកច្ឆាធម៌ជាមួយនឹងព្រះថេរៈជាធម្មកថិក ឬបណ្ឌិតឧបាសក ក្នុងថ្ងៃធម្មស្សវនៈជារឿយ ៗ រៀង ៗ មក ទ្រង់មានសទ្ធាជ្រះថ្លាមាំមួនណាស់ក្នុងព្រះពុទ្ធសាសនា ហេតុនេះហើយបានជារាជការជាធំ បានតាំងទ្រង់ឲ្យធ្វើជាអធិបតីនៃពុទ្ធសាសនបណ្ឌិត្យក្នុងកម្ពុជរដ្ឋនេះ ៗ

ក្រៅអំពីការដែលទ្រង់បានជួយផ្ទៀងផ្ទាត់ព្រះត្រៃបិដក ជាមួយនឹងក្រុមជំនុំពិសេសមួយ ដូចបានពោលមកហើយ ទ្រង់បាននិពន្ធរឿងផ្សេង ៗ ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយក៏មាន បោះពុម្ពផ្សាយក្រៅអំពីពុទ្ធសាសនបណ្ឌិត្យក៏មាន ដូចមានរាយឈ្មោះខាងក្រោមនេះគឺ ១-អនុត្តរិយសូត្រ, ២-មនោបុព្វកថា, ៣-អនត្តលក្ខណៈ

សូត្រ, ៤- បញ្ញាអគ្គិណ្ហបច្ចវេក្ខណៈ, ៥- បរមពុទ្ធសាសនកថា, ៦- បរម-ពុទ្ធភាសិត, ៧- ពុទ្ធសាសនកិច្ច, ៨- តិលក្ខណានុបស្សនា, ៩- ត្រៃសិក្ខា ១០- ទំនៀមការផ្លាស់ខ្លួន, ១១- ទ្រង់បានជួយផ្ទៀងផ្ទាត់ក្បួនរាជស័ព្ទនឹងសៀវភៅបក្ខគណនាវិធីជាដើម ។

សម្តេចព្រះរាជអយ្យកោ ទ្រង់ព្រះប្រឈួនដោយព្រះរោគជរា-ភាពមកជាវេលាយូរ អាការព្រះរោគជួនធូរជួនស្រាល ហើយតមកមិនយូរប៉ុន្មាន សម្តេចព្រះរាជអយ្យិកា ជាព្រះអគ្គជាយា ទ្រង់ព្រះប្រឈួនជាទម្ងន់ ហើយទ្រង់ព្រះវិលាល័យទៅមុន ។ តអំពីនោះមក អាការព្រះរោគសម្តេចព្រះរាជអយ្យកោជួនធូនជួនស្រាលមិនជាទីកំណត់ លុះមកដល់ថ្ងៃ ៧ ១៤ ៣ ឆ្នាំរកាសប្តស័ក ពុទ្ធសករាជ ២៤៨៨ (តាមប្រក្រតិទិនច័ន្ទ) ទ្រង់សោយទិវង្គតដោយព្រះរោគជរាភាព គង់កំណត់ព្រះជន្មាយុ ៧៣ ព្រះវស្សា ត្រូវនឹងថ្ងៃ ២៧ ខែយ៉ាំងវីយេ ឆ្នាំ ១៩៤៥ វេលាម៉ោង ១៨ និង ១០ មិនុត ។

ដំណឹងសោយទិវង្គតនៃសម្តេចព្រះរាជអយ្យកោនេះ នាំឲ្យកើតវិយោគសោកសោកជាយ៉ាងក្រៃលែង ចំពោះដល់ព្រះរាជវង្សានុវង្ស ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីធំ-តូចទាំងពួង ដរាបដល់ប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូល ។ តាមដោយពិត នៅក្រុងភ្នំពេញទើបតែទទួលវិប្បយោគទុក្ខថ្មីៗ មិនទាន់ជាស្រាកស្រាលស្បើយាលចិត្ត ដោយសម្តេច

ព្រះរាជអយ្យិកា សោយព្រះវិលាល័យទៅថ្មីៗកន្លងពីរបីខែមុននេះ ស្រាប់តែមកពើបប្រទះលើខ្លួនថ្មីនេះថែមទៀត ។ នៅវេលាមុនសោយព្រះទិវង្គតនោះ អាការព្រះរោគមិនជាធ្ងន់ប៉ុន្មានទេ ហេតុនេះបានជានៅវេលាសោយទិវង្គត ហាក់ដូចជាទ្រង់មិនបានសោយទុក្ខវេទនាឡើយ មានព្រះដំណើរដោយស្រួលក្ស តាំងនេះដោយព្រះរាជ-កុសលបុញ្ញរាសី ដែលទ្រង់បានអប់រំមកជាអនេកប្រការ ជួយឧបត្ថម្ភឲ្យទ្រង់មានព្រះរាជដំណើរ យាងទៅកាន់បរលោកនាយ ដោយក្សេមក្សាន្តសម្រាន្តព្រះហឫទ័យ ។

ក្រសួងពុទ្ធសាសនបណ្ឌិត្យដែលមានទ្រង់ជាអធិបតី សូមបង្អោនកាយ-វាចា-ចិត្ត ចូលកាន់មរណសញ្ញាដោយសេចក្ដីគោរព ចំពោះព្រះសពទ្រង់ព្រមទាំងនឹករលឹកឃើញ ព្រះឧបការគុណរបស់ទ្រង់យ៉ាងជាក់ច្បាស់ ទើបថ្វាយសៀវភៅផ្សេងៗ ដែលទ្រង់បាននិពន្ធមានចំនួនជាង ១ ពាន់សៀវភៅ ជាអំណោយរបស់ក្រសួងដោយសេចក្ដីគោរព សម្រាប់ចែកជាធម្មបណ្ណាការ ថ្វាយព្រះរាជកុសលក្នុងឱកាសបុណ្យព្រះមេរុ ពីថ្ងៃ ២ ដល់ថ្ងៃ ៩ កើតខែមាឃ ព.ស. ២៤៩៨ ត្រូវនឹងថ្ងៃ អង្គារ ៣០ ហ្សង់វីយេ ដល់ថ្ងៃ អង្គារ ៦ ហ្វេវ្រីយេ ឆ្នាំ ១៩៥៥ នេះ ៕

## រឿងការរបស់លោកពុទ្ធ ជាតិចិន ១ រូប

### ឈ្មោះហួន-ឆាង

### ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

ស្រង់និងប្រែចេញអំពីសៀវភៅ Religieux et pelerins en terre d'Asie របស់លោក Goloubew សមាជិកសាលាបារាំងសែសនៅចុងបូព៌ាប្រទេស

(តមក)

តែខ្លួនលោកមើលឃើញតែម្នាក់ឯងយ៉ាងជាក់ស្តែង ៗ ឯពួកសត្វទាំងនោះគឺប្រាកដជាពួកព្រះអរហន្តក្នុងព្រះពុទ្ធសាសនាហ៊ីនឯង ទើបលោកស្រែកហៅឲ្យពួកព្រះអរហន្តទាំងនោះជួយលោក អំពីបំណងចង់ធ្វើដំណើរទៅនោះ ហើយលោកសុំឲ្យកើតមានជាប្រផ្នូលល្អមួយឡើងឲ្យប្រាកដជាក់ស្តែងដល់ខ្លួនលោក ៗ តមកមិនយូរប៉ុន្មានក៏កើតមានប្រផ្នូលនោះឡើង គឺក្នុងយប់មួយ លោកយល់សប្តិឃើញភ្នំព្រះសុមេរុ ដែលជាព្រះភ្នំដ៏សក្តិសិទ្ធិរបស់ពុទ្ធសាសនិកជនទាំងឡាយ ៗ ភ្នំនោះប្រដាប់តាបពេញទៅដោយពេជ្រនិងរតនៈមានដំរៀងទាំងអស់ ដុះកើតឡើងយ៉ាងរុងរឿងមានស្ទើរព្រោះព្រាតនៅកណ្តាលមហាសមុទ្រ ៗ ឯខ្លួនលោកហួន-ឆាង ក៏ខំព្យាយាមទឹងទៅឲ្យដល់ទៅភ្នំនោះ តែនៅក្នុងសមុទ្រមានរលកធំៗ ជេរដាសៈដោយពពុះទឹកបោកបែកផ្កាត្រែង គួរឲ្យស្រៀវខ្លាចជាពន្ទឹក លោកនឹកគិតដាច់ស្រេចក្នុងចិត្តក៏លោកចុះទៅ ៗ ក្នុងមួយរំពេចនោះ ស្រាប់តែមានផ្កាឈូក ១ ដុះផុលឡើងទ្រជើងលោក

ព្រួតមកបន្តិចក៏ស្រាប់តែបានទៅដល់ដើមឈើនោះ ហើយមានខ្យល់កួច ១ កើតឡើងភ្លាម កួចនាំយកខ្លួនលោកទៅដាក់លើកំពូលភ្នំសុមេរុ ដែលខ្ពស់ជាងគេ ។ លោកហួន-ធាន បានក្រឡេកមើលអំពីទីនោះទៅ សព្វទិសទាំងពួង ឥតមានកំបាំងទំនងក្នុងលោកឡើយ ក្នុងយល់សប្តិនោះជាលោកមានសេចក្តីត្រេកអរពេកណាស់ ក៏ភ្ញាក់រលឹកឡើង ។ តពីពេលនោះមកបន្តិច លោកហួន-ធាន ក៏ចេញដំណើរទៅប្រទេសទិសខាងលិច ។

— ៣ —

មានពួកមន្ត្រីទីងមេតាហានជាច្រើន ដែលមានសទ្ធាជ្រះថ្លាជួយលាក់លៀបបំបិទបំបាំង ដើម្បីជួយឲ្យលោកពុទ្ធគុន (ហួន-ធាន) ចូលតំបន់ដែលមានអំណាចចិនត្រួតត្រា ក៏ទៅបានមិនពិបាកពេក លុះតែបានចូលផុតពីកំពែងធំទៅ ។ លោកដំដើរទៅស្រាប់តែប្រទះមហាសមុទ្រខ្សាច់មួយ មើលទៅឃើញធំល្វឹងល្វើយដាច់កន្ទុយភ្នែក ។ លោកដំដើរកាត់ទៅមុខតែម្នាក់ឯង ដោយមានសេះពាស់ ១ មានពេមក្រហមជាយានជំនិះ ។ ត្រូវយាត្រាកាត់ទៅតាមចំរុយផ្លូវ ដែលមានតែភក់ឆ្អឹងរបស់មនុស្សនឹងឆ្អឹងដែររបស់សត្វខ្ពង់ទាំងឡាយ ក្រោយពួកខ្លាខ្លាបនៅតាមផ្លូវដែលពួកកាភាកិន(១) តែងគេដើរទៅ ។ លោកហួន-ធាន

---

១ កាភាកិន គឺពួកក្រុមអ្នកដំណើរឬអ្នកជំនួញ ដែលតែងតែដើរឆ្លងកាត់សមុទ្រខ្សាច់ហៅថា ពួកកាភាកិន ។

លោកប្រែមូលប្រមោលលោកដោត្រៃស័យ ខ្លួនលោកស្ទើរតែនឹងក្សិណក្ស័យជីវិត ដោយការប្រែកឃ្លានជាច្រើនលើកច្រើនគ្រា ហើយដូចជាពួកអ្នកដំណើរដែលត្រូវទៅមកនោះ តែងបានជួបនឹងពួកបិសាចក្នុងសមុទ្រខ្សាច់យ៉ាងណា ឯលោកហ្វូន-ឆាងក៏បានឃើញនិមិត្តប្លែកៗ ដែលនាំឲ្យលោកព្រឺព្រួចិត្តជាខ្លាំងដូចគ្នាដែរ ។ នៅវេលាយប់ ពួកបិសាចកំណាច ក៏នាំគ្នាដុតភ្លើងភ្លឺព្រោងព្រាតនៅជុំវិញខ្លួនលោកដូចជាភ្លើងចន្លុះ មានចំនួនច្រើនណាស់ដូចជាផ្កាយនៅលើមេឃ ។

——ដល់វេលាថ្ងៃ លោកបានសង្កេតទៅ ឃើញពួកមនុស្សកាន់អាវុធជាច្រើនអំពីចម្ងាយ ហើយសុទ្ធតែស្លៀកពាក់សំពត់ស័ក្លាត និងសំពត់រោមសត្វ មនុស្សទាំងអស់នោះដូចជាពួកចោរតាដេប (ឥតទីសំ-ណាក់) ដែលនាំឲ្យលោកមានសេចក្តីភ័យខ្លាចជាច្រើននៅវេលាដែលជួបប្រទះ ។ ពួកចោរ ១ ពួកនោះ ហាក់ដូចជាឈានដើរដោយជំហានវែងៗ នៅក្នុងពពកខ្សាច់ (គឺដីខ្សាច់ដែលត្រូវខ្យល់បក់គួចឡើងទៅអាកាសដូចជាពពក) ចោរមួយពួកទៀត ឈរនៅស្ងៀមមិនកំរើកខ្លួនសោះ តែក្រឡេកមើលទៅចំអ្នកដំណើរ គួរឲ្យស្ញប់ស្ញែង ចាំគន់មើលអំពីចម្ងាយដោយកិរិយានឹងថ្កល់ ។ មានជាលំពែងភ្លឺផ្លេកចាប់ពន្លឺថ្ងៃ មានទង់ជ័យបក់រវិចៗ ដោយខ្យល់បក់ ។ មានពួកខ្ម

ដើរទៅជាជួរៗ ហើយមានពួកសេះសុទ្ធតែខ្លាយកទង់ ស្រែកពេញ គ្រវីសក់របស់វា... ហើយមួយពួកទៀតនោះ មានជារូបពស់សុទ្ធៗ មួយពួកទៀត ជារូបស្រមោលបិសាចយ៉ាងចំឡែកៗ លុះពួកនោះកាឡាដំណែនខ្លួនជាច្រើនយ៉ាង ផ្លាស់ប្រែរូបជាច្រើនយ៉ាងបានឆាប់រហ័ស គួរឲ្យខ្លាចពន់ពេក ហើយនៅទីបំផុតពួកនោះក៏សន្ទប់ចាំងអស់ទៅៗ នៅវេលានោះស្រាប់តែឮសូរសំឡេងចេញមកអំពីផ្ទៃមេឃឮសូរណាទៀតថា "អ្នកកុំខ្លាចឡើយ, អ្នកកុំខ្លាចឡើយ" ។ ហើយលោក ហួន—ឆាង ក៏មានសង្ឃឹមជួបចិត្តតំរិតនឹងមានកំឡាំងកំហែងមាំមួនឡើងវិញភ្លាម ហើយចាប់ផ្តើមចេញដំណើរដើរទៅតែម្នាក់ឯង នៅកណ្តាលវាលដីរំលេងហួតហែងគួរខ្លាច លោកដើរសំដៅទៅទិសខាងលិច ដោយដំណើរយឺតៗ និងលំបាកជាច្រើន ។

លុះដើរទៅតាមឆ្នេរសមុទ្រខ្សាច់ក្បែរទិសខាងត្បូង លោកក៏បានដល់ទៅប្រទេសរបស់ស្តេចគួហ្វាន ។ ប្រទេសនេះ មានឈ្មោះតាមភាសាចិនហៅថា កាវ-ចាង ជាប្រទេស១ ដល់មកសតវត្សទី៧ ជាអាណាចក្រមានទ្រព្យអំណាច និងមានសេចក្តីរុងរឿងជាច្រើនៗ ពួកអ្នកស្រុកក្នុងប្រទេសនោះ សុទ្ធតែជាក្រស្តជាតិតួជ ឥ ល្ហា- ទុរុប ជាខ្សែស្រឡាយជាមួយនឹងជាតិតួកទៀត ពស្ត្រាំងនោះច្រើនជាអ្នក

បានសម្បត្តិស្តុកស្តម្ភ ដោយធ្វើជំនួញជាមួយនឹងចិន នឹងប្រទេសប៉ែរ្ស-សាសានីត ៗ ជនទាំងនោះមានចំណេះចេះដឹងខាងភាសាសំស្ក្រឹត នឹងកាន់ព្រះពុទ្ធសាសនាដែលបានទទួលមកអំពីប្រទេសឥណ្ឌា ហើយជាអ្នកគោរពប្រតិបត្តិតាមព្រះពុទ្ធសាសនាដោយសទ្ធាជ្រះថ្លាផង ៗ នៅវេលាដែលស្តេចត្រកូលប្រទេសក្នុងហាន ទ្រង់បានជ្រាបថា មានគម្ពីរព្រះពុទ្ធសាសនានិមន្តមកពីប្រទេសចិន ដើរកាត់ប្រទេសរបស់ទ្រង់ ដើម្បីទៅប្រទេសឥណ្ឌា ទ្រង់ចាត់ឲ្យមានក្បួនហែទទួល ដោយទ្រង់ហែខាងក្បាលក្បួន នៅខាងមុខលោកពុទ្ធគ្គនោះ ហើយនិមន្តលោកចូលទៅឲ្យគង់ក្នុងវាំងរបស់ទ្រង់ ៗ លោក ហួន-ឆាង ក៏ទទួលបដិសណ្ឋារៈនោះ ប៉ុន្តែក្សត្រក្នុងហានដោយទ្រង់សព្វព្រះទ័យនឹងចំណេះចេះដឹងដ៏ធំទូលាយរបស់លោក ព្រមទាំងកិរិយាវាចាដ៏សមរម្យគួរជាទីជ្រះថ្លានោះ ទ្រង់មានប្រាថ្នាចង់ឲ្យលោកហួន-ឆាងគង់នៅជិតក្បែរទ្រង់ ប៉ុន្តែលោកបានតាំងចិត្តដាច់ស្រេចថា ទោះបីស្លាប់ដោយអត់បាយក្តី អត់ទឹកក្តី ក៏មិនត្រឡប់បង់បំណងដើមរបស់លោកឡើយ ៗ លោក "ស៊ូតែគង់នៅ ដោយឥរិយាបថត្រង់នឹងថ្កល់ ឥតកម្រើកបន្តិចរហូតដល់ ៣ ថ្ងៃ ឥតមានទឹក ១ ដំណក់ឬបាយ ១ ស្លាបព្រា ជ្រាបចូលទៅក្នុងបំពង់កលោកឡើយ ៗ ទើបព្រះ

មហាក្សត្រតួរហ្វាន ទ្រង់ឈ្លានសេចក្តីភិតភ័យនឹងភៀនខ្មាសជាច្រើន ទើបទ្រង់ក្រាបថ្វាយបង្គំដល់ដីចំពោះមុខលោក នឹងទ្រង់បង្គំសុំខមាទោសលោកដោយសេចក្តីគោរពផង" ។

— ៤ —

លោកហួន-ឆាងនោះ ក្រោយដែលបានថ្វាយព្រះពរលាព្រះកដាជាមិត្តនឹងជាព្រះកដូបត្ថម្ភហើយ ក៏ចេញចាកតំបន់ដ៏ស្ដុកស្ដម្ភនៃរឿងអំពីនគរតួរហ្វាន ហើយចាប់ដើរសំដៅទៅទិសខាងលិច ។ រយៈសំបកលើកទី ២ នៅកុតធា ជាទីក្រុងសំខាន់មួយទៀតនៃទ្វីបអាស៊ីកណ្ដាល ហើយជាទីប្រជុំប្រតិបត្តិតាមច្បាប់នៃព្រះពុទ្ធសាសនា ។ លោកហួន-ឆាងបានឈប់សំណាក់នៅក្នុងនគរនោះជាង ៦០ ថ្ងៃ ដើម្បីរង់ចាំឲ្យហិមៈនៅភ្នំរលាយអស់ពីផ្លូវ ដែលជាគ្រឿងទំនាស់ដល់ដំណើរដើរកាត់ភ្នំទៀន-ចាន ។ នៅវេលាដែលលោកចេញដំណើរទៅនោះ ស្ដេចត្រង់កជ្រនគរកុតធា ស្មារណាគិតបាន ទ្រង់ព្រះរាជទានពួកមនុស្សបំរើដល់លោក ព្រមទាំងឧដ្ឋ សេះសម្រាប់ផ្ទុកគ្រឿងបណ្ណាការជាច្រើនផង ។ ក្រោយដែលលោក ហួន-ឆាង បានដើរកាត់ភ្នំទៀន-ចាន ដ៏ដេរដាសទៅដោយហិមៈរួចលោកនិមន្តដើរទៅតាមមាត់បឹងអ៊ីស្សិកគួលទានដើង ក៏បានចូលទៅសំណាក់នៅតក់ម៉ុតជាវេលាយូរ ជាទីដែល

ស្ដេចគុនស៊ីបតូ ក៏គង់នៅដែលជាស្ដេចធំរបស់ពួកជនជាភ័ក្ដរកែវិស ហានលិច ។ ស្ដេចអង្គនេះមានរិទ្ធិអំណាចគួរឲ្យស្ញប់ស្ញែង ជានាយករបស់ពួកជនទ្រង់កើតមកមុនជាយូរ នៃពួកកាម៉ែរឡូន និងពួកសង្សៀស-វា ទ្រង់បានធ្វើឲ្យលោកហ្វូន-ឆាង ស្ញប់ស្ញែងកក់ស្លុតដោយឫកពាជាអ្នកចម្បាំង ហើយពួកបរិវារក៏សំដែងការគោរពយ៉ាងអ៊ឹកធឹកណាស់ដែរ ។ ក្សត្រអង្គនេះ មិនមែនជាអ្នកកាន់ពុទ្ធសាសនាទេ តែទ្រង់ចូលចិត្តឲ្យពួកលោកសង្ឃធំៗ អធិប្បាយ ពន្យល់អំពីរបៀបច្បាប់ធម៌ដែលល្អ ហើយចូលចិត្តជជែកជាមួយនឹងលោកទាំងនោះ ។ ស្ដេចនេះក៏បានយកគាត់ទាំងពីរលោក ដោយចង់ឲ្យលោកគង់នៅជិតៗទ្រង់ មានចំណងដូចជាស្ដេចគួរហ្មានបានធ្វើមកហើយ ។ ទ្រង់មានព្រះបន្ទូលថា “លោកគ្រូ មិនគួរលោកនិមន្ត ទៅប្រទេសឥណ្ឌៀឡើយ ដ្បិតប្រទេសនោះអាកាសក្ដៅខ្លាំងណាស់ ក្នុងផ្លូវដ៏អាកាសក្ដៅខ្លាំងជាងប្រទេសយើង ក្នុងផ្លូវក្ដៅទៅទៀត . . ។ ខ្ញុំមើលទៅមុខលោកខ្ញុំខ្លាចបាត់លោកទៅនៅវេលាទៅដល់នោះឯង ។ ឯពួកអ្នកស្រុកនោះទៀត សុទ្ធតែជាមនុស្សខ្មៅៗ ដើរខ្លួនទទេ ហើយដោយប្រែននោះជាមនុស្សមិនចេះចងសណ្ឋានៈគួរសមគួរទេ ជនទាំងនោះមិនសមគួរលោកនិមន្តទៅមើលគេឡើយ” ។ ប៉ុន្តែលោកហ្វូន-ឆាង

ញញឹមយ៉ាងទន់ភ្លន់ឆ្លើយតបទៅវិញថា "ដូចទ្រង់តែងឃើញស្រាប់ អាត្មាភាពមិនអាចកំចាត់បំបាត់បំណងយ៉ាងខ្លាំងក្លារបស់អាត្មាភាពបានទេ, គឺការទៅសួរស្វែងរកព្រះធម៌ និងវិសុទ្ធរបស់ព្រះពុទ្ធជាម្ចាស់ ហើយពិនិត្យមើលរតនបុរាណទាំងឡាយ ដែលកន្លងទៅហើយ ដើម្បីធ្វើដំណើរដើរទៅតាមស្នាមព្រះបាទ របស់ព្រះពុទ្ធ ដោយសេចក្ដីស្មោះស្ម័គ្រ" ទើបក្សត្រជានាយកជាតិតួរគ៏ ក៏តាំងឱនព្រះសិរចំពោះមុខលោកធុតង្គ ថ្វាយបង្គំដោយសេចក្ដីគោរពយ៉ាងខ្ពង់ខ្ពស់ ហើយបណ្ដោយឲ្យលោកនិមន្តចេញទៅ ព្រមទាំងបានរៀបចំបម្រុងទុកជាមុន អស់ទាំងគ្រឿងប្រដាប់ប្រដា ដើម្បីជូនដំណើរលោកនិមន្តចេញទៅបានដោយស្រួល ។

— ៥ —

លោកហួន-តាង ជាខាងក្រោយដែលបានដើរចូលទៅមើលស្រុកតាប់កេនហើយ លោកក៏ចាប់ផ្ដើមដើរកាត់តំបន់ស៊ុល-គុម គឺ "សមុទ្រខ្សាច់ក្រហម" ដែលគួរខ្លាចស្ញប់ស្ញែងណាស់ ។ សមុទ្រនេះឯងហើយដែលប្រែកប់ដោយសេចក្ដីវេទនាជាក្រៃលែង ដែលលោកឆ្លងដំណើរទំ-ដើរធ្ងន់ជាយូរអង្វែង ។ លោកបានកត់ត្រាទុកដោយខ្លួនលោកថា "ស-មុទ្រខ្សាច់នេះ ជាវាលខ្សាច់យ៉ាងធំសំបើម ហើយដាច់ឥតទឹកឥតស្មៅ

ផង ៗ ត្រូវក្រឡេកមើលទៅគ្រោងសត្វ ពីរបី ដែលនៅឆ្ងាយបន្តិចនោះ ហើយត្រូវតែងតែមើលគំនរឆ្អឹងខ្មោចដែលស្លាប់ចោលទៅ ទើបកំណត់ទីស្គាល់ផ្លូវដែលត្រូវដើរទៅនោះបាន " ៗ ទុកជាលំបាកយ៉ាងណាក៏ដោយ លោកហួន-ឆាង ក៏បានដល់ទៅស្រុកសាមារកន្ទដោយសួស្តី ស្រុកនោះជាទីក្រុងម៉ាស់រឿង ជាទីកុះករដោយអ្នកជំនួញទំនិញពួកតាក់-កាំង ជាស្រុកប្រើដោយភាសាសុកដៀន ៗ លោកចំដើរសំដៅត្រង់ទៅទិសខាងត្បូង ៗ លោកចំដើរកាត់ជួរភ្នំហិណ្ឌូកូះដែលនៅខាងចំណែកស្រុកបាមៀ ហើយចូលកាត់ទន្លេ អាមូ-ដារយ៉ា តាមពាក្យបុរាណហៅថាទន្លេវក្សុ ត្រង់កន្លែងជួនហៅថាបាតា-កេសារ ហើយលោកចូលទៅស្រុកបាក់ទ្រីយ៉ាន ជាទីខេត្តដ៏ថ្កុំថ្កើង ១ របស់ជាតិអារីយ៉ង់ តាំងពីសម័យស្ដេចអាលេក្សង់ដ្រឺមហារាជចូលលុកលុយកាន់យកបាន ៗ កាលពីក្នុងជំនាន់លោកហួន-ឆាងនោះ ប្រទេសនោះ នៅខាងរក្សាដំណែលពុទ្ធ-សាសនាជាច្រើននៅឡើយ ៗ គេរាប់ទៅឃើញមានចំនួនវត្តច្រើនដាន់ពេលៈឡើងទៅ ជាទីបរិបូណ៌ដោយព្រះសារីរិកធាតុតាំងឡាយ ហើយមានចំនួនភិក្ខុជិតដល់ ៣,៩១០ អង្គផង ៗ នៅស្រុកបល្ខ ដែលជាទីក្រុងរបស់បាក់ទ្រីយ៉ាននោះ លោកហួន-ឆាងបានជួបប្រទះលោកអ្នកប្រាជ្ញធំ ១ រូប កាន់ពុទ្ធសាសនាបែកមហាយាន ឈ្មោះលោក

ប្រាជ្ញករៈ ។ លោកអ្នកប្រាជ្ញនេះបានឆ្លើយដោះស្រាយអំពីសេចក្ដីប្រស្នាខ្លះក្នុងព្រះអភិធម្ម ដែលលោកហ្ស៊ួន-ឆាងបានចោទសួរលោក ព្រមទាំងសេចក្ដីព្រះសូត្រឯទៀតៗ ទៀត ដែលបានជ្រើសរើសយកត្រង់កន្លែងដែលពិបាកណាស់ ។

កាលលោកហ្ស៊ួន-ឆាងបានដើរកាត់ស្រុកបក់ទ្រីយ៉ាន តាំងពីដើមរហូតដល់ចុងហើយ លោកក៏ដើរកាត់ភ្នំឈ្មោះហិណ្ឌូ-គូស ដែលជាភ្នំមានកំពូលជាប់ដេរដាសដោយហិមៈជានិច្ច ហើយមើលទៅខ្ពស់ត្រដែតទៅចោលមេឃៈនៅចំពោះមុខលោក ។ លោកត្រូវតែឡើងកាត់ភ្នំដែលមានកំពស់ខ្ពស់ត្រដែត ដើម្បីឲ្យបានដល់ទៅផ្លូវ ដែលគេតែងដើរទៅរកច្រកភ្នំខ្ពស់ៗ (ជាកំរុយផ្លូវ) នៅស្រុកអាហ្វ្កានីស្ថាន ។ លោកហ្ស៊ួន-ឆាងក៏បានជួបប្រទះនឹងសេចក្ដីលំបាកវេទនា ប្រកបដោយសេចក្ដីអន្តរាយជាច្រើនទៀត ។ លោកតោងដើរកាត់ដុំពពកហ៊ោងក្រាស់ដែលចាប់គាំរឹងដូចជាទឹកកក ហើយមានខ្យល់អាកាសនោះស្ទើរតែដាច់ដង្ហើមមិនរួច ។ នៅផ្លូវដើរដែលលោកដើរទៅនោះ ខ្ពស់ៗ ចោតៗ ក្រហេងក្រហូង មានហិមៈជាន់ទៅជុំវិញ មុខគួរឲ្យស្ញប់ស្ញែងខ្លាចជាពន្លឹក ហើយលាន់ឮសូរទឹកហូរ និងប្រឡាយទឹកហូរ ឮសូរគគ្រុកគគ្រាកគគ្រាក់ ៗ មួយទៀត ព្រោះហេតុមានអន្តរាយពីគ្រប់ ប្រាកដថែមទៀត

ទៀត កើតមកពីបិសាចកំណាចទាំងឡាយ ដែលរមែងមកនៅជិតប្រកិតជា-និច្ច រមែងតែងធ្វើឲ្យមានអន្តរាយគ្រោះថ្នាក់ដល់អ្នកដំណើរ ដោយប្រាន ទម្លាក់ដុំទឹកកកសង្កត់ ឬធ្វើឲ្យវង្វេងវង្វាន់ក្នុងចំណោមភ័ព្វហិមៈនោះឯង ។ លោកហ្វូន-ឆាងបាននិយាយរំលឹកជាច្រើនដង នៅក្នុងសៀវភៅកំណត់ត្រារបស់លោក ហើយលោកបានខ្លាចយ៉ាងស្មោះត្រង់ អំពីគ្រោះថ្នាក់អន្តរាយទាំងនោះ ចំពោះពួកអ្នកដែលប៉ុនប៉ងនឹងដើរឆ្លងទីនោះទៅ នៅវេលាជាខាងក្រោយអំពីលោកមក ។

— ៦ —

លោកពុទ្ធគមន៍និងគណៈអ្នករួមដំណើររបស់លោក បានទាំងឃ្លាតដើរផ្លូវយ៉ាងលំបាកវេទនា ត្រាតែផុតឬដើរនឹងទីសំចតដែលលំបាកទៅបាន លោកអស់នោះ ក៏បានដល់ទៅជើងភ្នំនៅខាងត្បូងភ្នំហិណ្ឌូគូស ហើយក៏នាំគ្នាដើរចុះទៅតាមផ្លូវដែលល្អនឹងស្រួលទៅស្រុកបាមយ៉ាន លោកអស់នោះក៏សឹងមានចិត្តរីករាយរាល់គ្នាជាពន្ទឹក ៗ កាលបានដល់ទៅស្រុកបាមយ៉ានហើយ លោកហ្វូន-ឆាងក៏បាត់នឿយហត់អស់កំឡាំងភ្លាម ៗ នៅខាងជើងទីក្រុងនោះ មានញកក្តូខ្ពស់ ៗ លយចេញពីភ្នំទៅ នៅពីខាងក្រោមមានរោងជាចំនួនច្រើន ជាទីស្នាក់អាស្រ័យនៅនៃពួកភិក្ខុពុទ្ធសាសនា ។ (មានត)

ពត៌មានថ្លែងសេចក្ដី

កាលទៅនាំយកព្រះពុទ្ធរូបនិងបល្ល័ង្កនៅឃុំអង្គរបុរីស្រុកព្រៃកប្បាស

(តាកែវ)

ឃុនបញ្ញាសោភ័ន តាំ - ឌុម រៀបរៀង

(តយក)

ក្នុងវេលាល្ងាចថ្ងៃ ៦ នោះឃើញតែទូកចូលទៅកំពង់ផាហូរហែគឺពួកយួនដែលមកពីភូមិផ្សេងៗ ចូលទៅបំរុងធ្វើបុណ្យជួបជុំគ្នានៅវត្តព្រះនាគយណ៌ កាលបើទៅដល់ឃើញបាត់ព្រះនាគយណ៌ពីកន្លែងដូច្នោះហើយ ក៏នាំគ្នាធ្វើមុខស្រពោនស្រងូតស្រងាត់គួរមានចិត្តអាណិតអាសូរណាស់ ។

## អំពីយកព្រះពុទ្ធរូបក្នុងគុហាទី ២ (ភ្នំដា)

ថ្ងៃ ៧ សេបតម្ប្រ៍ ពេលម៉ោង ១០ ព្រឹកបាប់ប្រារគ្នាទៅយកព្រះពុទ្ធរូបក្នុងគុហាទី ២ យួនហៅថា ជួងកសឹងក្រែតទៅទៀត ឯរបៀបចាត់ចែងនិមន្តព្រះពុទ្ធរូបចេញពីគុហាចុះទៅដាក់លក្នុងទូក ជាភារៈលើថយួនជាវិស្វករម្នាំង ៤ នាក់ជាមេចាត់ការ ឯយើងខ្ញុំគ្រប់គ្នាគ្រាន់តែជួយហែហមប៉ុណ្ណោះ ដោយហេតុក្រសួងសាធារណការចាត់ការមានរបៀបគួបតែងអែបអបចលវ់ទ្រញ៉ុកញ៉ាក់ច្រើនពេក ការនិមន្តព្រះពុទ្ធរូបត្រឡប់ទៅជាយឺតយូរបន្តិចស្ទើរតែ ១ ថ្ងៃទើបហើយ ឯពួកយួនអ្នកស្រុក

កាលដែលយករូបបុកណាមកចូលស៊ីម៉ង់ត៍ ប៉ះប៉ុនកែកុនជាព្រះពុទ្ធរូបឡើងវិញនោះរាប់ជាង ២០ ឆ្នាំហើយ ដល់កន្លងមកខាងក្រោយ មានជាតិបារាំងម្នាក់ជាមេត្រួតត្រាបុរាណវត្ថុកាលដែលទៅជួសជុលប្រាសាទភ្នំដាទីនគា ស្រមមហាឫស៊ីបានយកកំណាត់ដៃជើងពីទីនោះ ប្រហែលជាទុកនៅក្នុងសារមន្ទីរភ្នំពេញដែរ? ឯបុរាណវត្ថុដទៃក្រៅអំពីព្រះពុទ្ធរូបនេះទៅ មានកំណាត់ចុងជើងស្តាំ ១ តួប ធ្វើអំពីសំរិទ្ធ ទម្ងន់ ៣៤ ក្រាម បានយកមកជាមួយផងដែរ ។

លុះនិមន្តព្រះពុទ្ធរូបទៅស្ណិតនៅក្នុងទូករួចជាស្រេច ក្នុងវេលាម៉ោង ៤ រសៀលហើយយើងខ្ញុំក៏នាំគ្នាទទួលទានអាហារ ហើយលោកពួកយួនចេញពីភ្នំដានៅវេលាម៉ោង ៥ រសៀលថ្ងៃ ៧ ប្រញាប់ទឹងវិលទៅយកបល្ល័ង្ក (ស្ពានទ្រាណី) ពះលើភ្នំបាទេពក្នុងវេលាព្រឹកស្អែកថ្ងៃ ៨ សេបតម្ប៊ែរទៅទៀត ឯពួកយួនភ្នំដាឃាត់យើងគ្រប់គ្នាឲ្យនៅចាំមើលបុណ្យក្នុងវេលាល្ងាចថ្ងៃ ៧ នោះសិន តែយើងខ្ញុំពុំព្រមនៅហើយក៏ចេញទូកទៅសំដៅភ្នំបាទេព ដែលនៅទិសឦសានភ្នំដាចម្ងាយប្រ-ហែល ៣.០០០ម. លុះទៅដល់ពាក់កណ្តាលផ្លូវទើបឮសូរស្គរឃោះគោះដំគ្រាំគគ្រេងដែលពួកយួនទាស់គេងប្រជុំគ្នា ធ្វើបុណ្យនៅទីវត្តព្រះនាគយណ៍ ឮសូរពីចម្ងាយគួរឲ្យសប្បាយរីករាយអណ្តែតអណ្តូងក្នុងចិត្ត លុះជិតដល់ទៅភ្នំបាទេពស្រាប់តែពពកខ្មៅខ្ទួលខ្ទាញ់ មេឃងងឹតជិត

សុទ្ធធ្លាក់ក្បៀនផ្លូវទ្រនុះលើគោកាសស្ពាន ពិបាកនឹងរកផ្លូវចូលឡើងដល់ភ្នំបា-ទេពបាន ព្រោះទឹកកក់ពេកកប់ឈ្លួសទូកចូលទៅបកទទួលពានដំណាក់នៅទួលផ្ទះសេហ៊ុំបុស្ដិ៍ ឯពួកជាងយួនវិស្វកម្មក្រសួងសាធារណការគោគែរ ក៏បែរទូកទៅសំណាក់នៅឯចំអន្ទរប៉ុរ ។

## អំពីយកបល្ល័ង្កស្ពានទ្រោណីពីលើភ្នំបាទេព

ថ្ងៃ ៨ សេបតមប្រ៍ វេលាម៉ោង ៨ ព្រឹកបានចេញទូកទៅជួបជុំគ្នានៅភ្នំបាទេព ប៉ុន្តែដោយហេតុទឹកដែលឡើងទៅដល់ជើងភ្នំនៅកក់ណាស់ ក៏បានបកទូកឆ្ងាយស្រឡះបង្ហាយប្រហែល ២០០ ម. ពីជើងភ្នំ ហើយឲ្យពួកគូលីជញ្ជូនបេកគ្រឿងអន្ទងតីដែកនឹងឈើឡើងទៅលើភ្នំដាប់ផ្គុំឈើធ្វើជាឃ្នាបគាបបល្ល័ង្ក ប៉ាំងកុំឲ្យប៉ះទង្គិចបេះក្បាច់ស្រេចហើយ ទើបគ្រប់លើកបល្ល័ង្កឡើងអន្ទងដាក់ចុះទៅលើរទេះដែក ដែលដំកល់លើផ្លូវដែករៀបបន្តជំរង់ទៅក្បាលដំណើរ ដែលចុះពីលើភ្នំរហូតទៅដល់ជើងភ្នំ ដោយហេតុបល្ល័ង្កនោះមានទំហំធំណាស់ក៏ង ៤ ជ្រុងស្រាប់លើគ្នាជា ២ កំណាត់ ១ ខាងលើទំហំ ១ ជ្រុង ១ ម. ៤០ កំពស់ ០ ម. ៤៨, កំណាត់ទី ២ ខាងក្រោមទំហំ ១ ជ្រុង ១ ម, ៥០ កំពស់ ០ ម, ៣០, រួមកំពស់ទាំង ២ កំណាត់កំពស់ ០ ម, ៧៨ ដែលលើកយកមកនោះបានតែកំណាត់ខាងលើជាមុន, បល្ល័ង្កនេះឯងបើតាមពាក្យ

លោកវិស្វករតែងតែនិយាយថា   លោកនឹងយកតែ ១ ថ្ងៃឲ្យហើយជាស្រេច   តែសម្រេចដល់ទៅលើកយកគ្រាន់តែកំណាត់ខាងលើ ៤ ថ្ងៃទើបនាំទៅដាក់ដល់ទូកបាន   ហើយដោយថ្ងៃទី ៧ វេលាដែលគេបចុះពីលើភ្នំមកតាមផ្លូវដែកទាញទប់ដោយខ្សែកាបទាញ ។ មិនឈ្នះបាក់ដាច់ខ្សែកាបនោះធ្លាក់ចុះមកពីលើភ្នំតាមជណ្ដើរគំពស់ ៣០០ ម, ០០ ទាំងរម៉ាំងរមោករហូតទៅដល់ជើងភ្នំផង   ឱព្រះ! ព្រះអើយ! នឹកទៅព្រឺសម្បុរស្លាប់   ហើយភ័យ-ភរ ។   ដោយបានរួចជីវិតអំពីបល្ល័ង្កដែលធ្លាក់ពីលើភ្នំនោះឯង   ព្រោះកាលដែលគេលបល្ល័ង្កសំយុងចុះពីកំពូលភ្នំបានប្រហែល ៦ ម. ប៉ុណ្ណោះ   ទេះដែក   ក៏ធ្លាក់ចេញពីផ្លូវដែកទៅបានរហែកខ្សែទាញ   ទប់ទុកសិន   ជំយួនម្នាក់បានយកដែកគ្រឹបទៅគ្រឹបលើកពីខាងក្រោមដើម្បីជំរើឲ្យត្រូវតាមផ្លូវដែក ចំណែកខ្ញុំក៏ចុះទៅតាមផ្លូវដែកបំណងនឹងមើលទំនងផ្លូវពីក្រោមទៅ   លុះជំយួននោះគ្រឹបទៀតដរងផ្លូវពុំបាន   ហើយក៏ថយចេញទៅខ្លួនខ្ញុំទើបចុះទៅដល់ជើងភ្នំហើយធ្លាក់ចេញពីផ្លូវដែកប្រហែល ៦ ម. ប៉ុណ្ណោះ   ពេលនោះឯងក៏ដាច់ខ្សែកាបទាញធ្លាក់បល្ល័ង្កចុះមកក្បែរខ្លួនខ្ញុំនិងជំយួននោះ   បានជាខ្ញុំនិងជំយួនរត់ទាន់ហើយទះដៃផងភ័យ ហើយត្រេកអរដោយបានរួចអំពីសេចក្ដីស្លាប់   សមដូចពាក្យពុកណាថា   "អាយុមិនអស់   គ្រោះគ្មានគង់មានទេវតាជួយពុំឲ្យស្លាប់" ឯបល្ល័ង្កដែលធ្លាក់មកនោះមានរបេះក្បាច់

បន្តិចបន្តួច ដល់ថ្ងៃ ១១ រោចខែម្រហ៊ែន ៣ វេលាទើបបាននាំទៅ រៀបដាក់ទុកក្នុងទូករួចជាស្រេច ឯទ្រនាប់បល្ល័ង្កខាងក្រោមពុំទាន់បាន យកទុកដល់ថ្ងៃក្រោយ ព្រោះប្រញាប់ចេញទូកទៅអគ្គិបុរីដើម្បីរៀបចំ ទុកតែងគ្រឿងសក្ការៈរបស់ព្រះពុទ្ធរូបដោយល្អ ។ ថ្ងៃ ១១ រោចខែនោះ ជាថ្ងៃចំរើនព្រះបរិត្ត ធ្វើបុណ្យសម្ពោធឆ្លងព្រះពុទ្ធរូបទាំងប៉ុន្មានដែលបំរុង នឹងនាំមកដំកល់ទុកនៅសាលាខន្ធក់ពេញ បានចេញទូកទៅបណ្ដោយមាត់ ស្ទឹងក្បែរវិហារវត្តកំពង់ហ្លួង ពិធីនេះដែលទើបនឹងធ្វើកាត់មុខវិហារពិសាលា បណ្ដៀនសំពៅទៅមាត់ស្ទឹង ។

## អំពីពិធីបុណ្យនៅកង្ហរប៉ុំថ្ងៃ ១២-៩-៥៤

ពិធីបុណ្យនេះ មានរបៀបរៀបចំគ័កគឹកពន់ពេកក្រៃពេកណាស់ដោយ ចេស្ដានុភាពរបស់លោក ឡើរស៊ីដង់ និងព្រះបាទម្ចាស់ចៅហ្វាយ ខែត្រតាកែវ ។ បានឲ្យចៅហ្វាយស្រុកព្រៃកប្បាសបញ្ជាប់ដល់លោក សេហ្វប៉ុស្តិ៍ និងមេឃុំ ។ គង្គីបុរីគេណ្ឌបណ្ដោក ស្រុកឲ្យមកជាក់ដែងរៀបចំពិធី បុណ្យ តាំងពីវេលា ៩ ថ្ងៃមុន គឺបានធ្វើផ្លូវ ១ ជាថ្មីទៀត កាត់ពីវត្តកំពង់ ហ្លួងសំដៅទៅវត្តព្រៃយចង្វាយ ប្រវែង ៣០០ ម. ព្រោះផ្លូវចាស់តាម មាត់ស្ទឹងទឹកលិចប្រើការមិនបានស្រួល, បានរៀបចំសែនកុដិវត្តកំពង់ ហ្លួង ៣ ខ្នងដែលធ្វើមុខមិនទាន់រួចស្រេច រៀបដាក់ផ្កាតាទ្យាត្បូងហើយ ធ្វើផ្លូវខ្ពង់ខ្ពស់ក្នុងទីវត្តទាំងមូលគប់ដើមពោធិ៍ជាដំណាំវត្តពោលចេញជា

ប្រែនផង បានគុបតែង សាលាបញ្ចៀនវត្តកំពង់ហ្លួង ធ្វើសម្រាប់ដាក់ប្រជុំ បុណ្យ ឯក្នុងទីវត្តជ្រោយបានរៀបចំសាលាវត្តសម្រាប់ទទួលអស់លោកផង ។ ដែលអញ្ជើញទៅពីតាកែវនឹងភ្នំពេញ ឯខាងមុខវត្តជ្រោយបានរៀប ធ្វើជាផែបេតាដោយស្លឹកឈើសម្រាប់អស់លោកផង ។ ចូលទៅបោះទូក ហើយឡើងទៅប្រជុំបុណ្យ ។

ថ្ងៃ ១១ សេបតឹមប្រ៍ វេលាម៉ោង ៨ ល្ងាច និមន្តភិក្ខុសង្ឃបំរើនព្រះបរិត្ត ម៉ោង ១០ និមន្តលោកគ្រូអាចារ្យធំជាពម្នកជិកសំដែងធម៌ទេសនា រួចហើយមានល្បែងពួកយុវជន ១ វង់ នឹងក្មេងសៀម ១ វង់ ក្មេងខៃយ៉ាំ ១ វង់ លេងសម្រាប់ទស្សនាការកំសាន្តនៅទីវត្តកំពង់ហ្លួង ឯទីវត្តជ្រោយមានពួកភាបេ៉ ១ វង់នឹងក្មេងសៀមសម្រាប់វត្ត ១ វង់ លេងសម្រាប់ទស្សនាកំសាន្ត ។ បុណ្យនោះគួរឲ្យសប្បាយណាស់ក្នុងវេលាយប់ថ្ងៃ ១១ នោះ ប៉ុន្តែតាស់នឹងមានភ្លៀងពីក្បាលល្ងាចធ្វើឲ្យទំបុណ្យទាំងអស់ក្រខ្វក់ក្រខ្វាប់ដោយភក់បន្តិចផង ទាំងគ្រឿងបំភ្លឺកំពុស្សូវមានគ្រប់គ្រាន់ផង ។

ថ្ងៃ ១២ សេបតឹមប្រ៍វេលាម៉ោង ៩ ព្រឹក ពួកភិក្ខុសង្ឃចំនួន ២០០ អង្គនិមន្តទៅគង់ប្រជុំចាំទទួលអស់លោកផង ។ នៅសាលាបញ្ចៀន វត្តកំពង់ហ្លួងនឹងរៀបឲ្យពួកយុវជនចំនួន ៨០០ ឈរចាំគំនាប់ ជាជួរតាមផ្លូវដែលធ្វើចេញពីវត្តកំពង់ហ្លួងរហូតទៅដល់វត្តជ្រោយផង ដល់ម៉ោង ១១ ព្រឹក

ទើបអស់លោកធំៗ អញ្ជើញទៅដល់មានក្មេងសៀម គាប់ និងទូកងប្រ-ណាំងជាច្រើន ហែហមគ្រឹកគ្រេងអមផង អស់លោកធំៗ ដែលអញ្ជើញទៅនោះមានចំនួនច្រើន ប៉ុន្តែដែលខ្ញុំបានស្គាល់ប្រាកដនោះគឺ:

លោកឡឺញ៉ា ឡឺរេស៊ីដង់ តាកែវ ព្រមទាំងលោកស្រីនិង បុត្រ-ធីតា របស់លោក ។

លោក ប្រាក់-សារិន ព្រះបាទម្ចាស់ចៅហ្វាយខេត្តតាកែវ ។

លោក ឌុយ-ប៊ុង អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ

លោក ខាស-ណាល់ ឧកញ៉ាមហាវិទ្យាធិបតី សេនាបតីក្រសួងសិក្សាធិការ ។

លោក គ្រុស ទេគ្រប់គ្រងបុរាណវត្ថុនៅអង្គរ (សៀមរាប) ព្រមទាំងភរិយារបស់លោក ។ ល ។

លុះទៅដល់ហើយក៏ចូលចតទូកអែបនឹងផែ ដែលរៀបចំដោយស្លឹកទន្សែនៅមុខវត្តជ្រៃ ហើយឡើងពីទូកគមនាការដោយបាទបន្ទួសទៅវត្តកំពង់ហ្លួង សឹងមានក្មេងសៀមនិងពួកយុវជនឈរលើកដៃគំនាប់ជាប់គ្នាជាលំដាប់រៀងទៅ ដល់វត្តកំពង់ហ្លួងចូលទៅក្នុងទីប្រជុំថ្វាយបង្គំសំ-ណេះសំណាលនឹងភិក្ខុសង្ឃ ហើយថ្លែងការសុំព្រះពុទ្ធរូបបុរាណក្នុងវត្តកំពង់ហ្លួងចំពោះលោកគ្រូឃី-នុតជាចៅអធិការវត្តនោះ ទើបលោកអ្នកឧកញ៉ាមហាវិទ្យាធិបតី (ខាស-ណាល់) ប្រគេនគ្រឿងឥស្សរិយយស

ឈ្មោះអស្សរិទ្ធ (ម៉ៃដយ៍ស៊ីកលីយ៉េរ) ក្រុមកម្ពុជា ចំពោះលោកត្រឹយ-នុត ចៅអធិការវត្តកំពង់ហ្លួងព្រមទាំងសំពត់ទេសឯក ២ ផាប់ ឈើគូស ១០ ហោទីងសៀវភៅធម៌ជាច្រើនទៀតផង រួចហើយទើបលោកឌុយ-ប៊ុន អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ចំពាក់គ្រឿងឥស្សរិយយសឈ្មោះមុនីសារគុណ ចំពោះលោកម៉ុ-ឈឹម មេឃុំអង្គរបុរី ព្រមទាំងឲ្យឈើគូស ១ ហោផង ក្រៅពីនេះឃើញមានប្រគេនសំពត់ទេសឯក, ឈើគូសនិងសៀវភៅធម៌ខ្លះចំពោះលោកគ្រូចៅអធិការវត្តជ្រៃរួចហើយ ទើបព្រះសង្ឃសូត្រជយន្តោចំរើនពរជ័យមង្គលចប់ហើយទើបចេញពីទីប្រជុំ ចូលទៅទស្សនាមើលព្រះពុទ្ធរូបដែលគេដាក់តម្កល់នៅក្នុងទីនៃព្រះពុទ្ធរូប ក្នុងវិហារវត្តកំពង់ហ្លួងរួចស្រេច ទើបត្រឡប់ទៅពិសាភោជនាហារឯសាលាវត្តជ្រៃវិញ ដល់ម៉ោង ២ រសៀលត្រឡប់ពីវត្តជ្រៃឆ្ពោះទៅវត្តកំពង់ហ្លួងទៀតដើម្បីទស្សនាការពួកយុវនរហែលទឹកនិងទូក ២ គូប្រណាំងគ្នាដល់ម៉ោង ៤ រសៀលទើបឈប់ ហើយព្រះអង្គម្ចាស់ចៅហ្វាយខេត្តកណ្តាល ចែករង្វាន់ជាប្រាក់ដល់ពួកហែលទឹកនិងប្រណាំងទូក រួចហើយទើបអស់លោកធំៗចេញពីអង្គរបុរីនៅវេលាម៉ោង ៥ រសៀល ដោយទូកកំពង់ ១ ដែលរបនាដោយស្លឹកឈើមានលំអផ្សេងៗ សំដៅទៅសាលាស្រុកព្រៃល្វា មានរថយន្តនៅចាំទទួលក្នុងទីនោះស្រេចការបុណ្យត្រឹមប៉ុណ្ណេះ ។

ក្នុងវេលាល្ងាចថ្ងៃ ១២ សេចក្ដីប្រែនោះលោកមេឃុំៗ អង្គរបុរីទាំងឧបាសកខ្លះជំនុំគ្នានិងនិមន្តព្រះសង្ឃសូត្រពុទ្ធមន្តក្នុងវេលាយប់នោះព្រឹកនិមន្តព្រះសង្ឃឆាន់ជាកិច្ចបង្ហើយបុណ្យតទៅទៀត ព្រោះកាលដែលជួបជុំធ្វើបុណ្យថ្ងៃ ១២ នោះធ្វើតាមរបៀបរាជការ យើងរវល់គ្នាពុំទាន់បានគោរពប្រណិប័តន៍ព្រះពុទ្ធរូបជូនដំណើរឲ្យសមគួរនៅឡើយ ចំណែកខ្លួនខ្ញុំក៏បានចូលទៅក្នុងវិហារដើម្បីស្ដាប់ព្រះសង្ឃសូត្រពុទ្ធមន្តជាមួយនឹងលោកមេឃុំក្នុងវេលាយប់នោះដែរ ប៉ុន្តែចំណែកឧបាសក-សិកាពុំសូវឃើញទៅច្រើនទេ មានចំនួនប្រហែល ២០ នាក់ប៉ុណ្ណោះ ហើយច្រើនតែស្រីៗផង ឯលោកគ្រូចៅអធិការកាលដែលពួងណាំងជារាជការនឹងប្រគេនម៉ៃដយ ១ លោកពុំមានព្រះទ័យត្រេកអរត្រូវការនឹងចង់បានប៉ុន្មានទេ ប៉ុន្តែដល់បានឃើញរូបម៉ៃដយយកមកពិនិត្យមើលរឿយៗក៏កើតមានឆន្ទៈជាប់ចិត្តស្រឡាញ់ឡើង ថែមទាំងវេលាដែលខ្ញុំចូលទៅលេងនឹងលោកៗ បានឲ្យខ្ញុំមើលសេចក្ដីក្នុងក្រដាសសញ្ញាប័ត្រឲ្យស្ដាប់ លុះឮសេចក្ដីក្នុងសញ្ញាប័ត្រមានពាក្យថា . . . ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយស . . . ដោយមានគុណបំណាច់ក្នុងរាជការ ក៏រឹតតែមានចិត្តជ្រះថ្លាច្រើនឡើង ហើយឲ្យខ្ញុំមើលជាញយៗ ដើម្បីឲ្យពួកឧបាសក-សិកាដែលមកតាំងក្រោយបានស្ដាប់ផង ហើយលោកមានថេរដីកាប្រាប់ពួកឧបាសក

តាំងប៉ុន្មានថា បើព្រះករុណាម្ចាស់ជីវិតមានព្រះរាជឱង្ការប្រថាប់ត្រា ច្បាស់មកយ៉ាងនេះហើយ យើងនឹងទទួលព្រះឱង្ការពុំព្រមឲ្យព្រះពុទ្ធរូប ឯណាបាន ហើយបង្ហាញរូបមេដៃយឲ្យមើលឃើញគ្រប់គ្នាដល់វេលា ដែលលោកនិមន្តចូលទៅសូត្រពុទ្ធមន្តក្នុងវិហារជួបជុំឧបាសក-សិកាក្នុង យប់ថ្ងៃ ១២ សេបតេម្ប្រ៍នោះ លោកក៏ពាក់មេដៃយនោះជាប់នឹងជា-ក្រាបទៅផងដែរ ។

វត្តកំពង់ហ្លួងនេះបានពិនិត្យទៅឃើញថាប្រកាន់តាមទំនៀមទម្លាប់ ច្រើនណាស់នៅឡើយ ឯលោកគ្រូ ឃ៉-នុត ចៅអធិការវត្តនោះ លោកកាន់ខន្តីតឹងតែងណាស់ ខ្ញុំឮអ្នកស្រុកអង្គបុរីនិយាយប្រាប់ថា កាលពីដើមលោកកាន់វត្តប្រតិបត្តិ ១ ឆ្នាំស្រង់ទឹកតែម្តង តទងមកសព្វ ថ្ងៃនេះលោកបន្ធូរបន្ថយច្រើនណាស់ ហើយនៅតែង ១ ខែ ២ ខែ ស្រង់ ទឹកម្តង បើសិនជាយ៉ាងនោះពិតមែនគួរឲ្យអស្ចារ្យណាស់ ព្រោះមើល ទៅសាប់លោកក៏ហើយឡើងរលើប ធាត់ទ្រលុកទ្រលន់ពុកមាត់ពុក ចង្កាលោកតម្រើនទុកវែងៗ លោកជាអ្នកស្លូតស្លូតតាមមានមេត្តាករុណា ដល់អ្នកស្រុកទាំងក្រៅវត្តណាស់ ព្រមទាំងសត្វឆ្កែឆ្មាជាដើមដែលនៅ ក្នុងវត្តទៀតផង លោកមានពុទ្ធដីកាម្តងៗ ទំនងដូចជាកំប្លែងៗ មិនអស់ លើងធ្វើឲ្យអ្នកស្តាប់ស្គាល់ព្រះទ័យលោកមិនអស់ទេ ប៉ុន្តែរបៀបរៀប ចំវត្តការកម្មវិហារកុដិសាលាពុំទាន់រៀបរយស្អាតល្អទេ ដោយអំណាច

មេឃុំទីនេះសេឡាប៉ុស្តិ៍ ខំប្រឹងខ្នះខ្នែងរៀបចំក៏បានទៅជាវត្តមានរបៀបករបន្តិចឡើង បើតាមព្រះទ័យរបស់លោកគ្រូចៅអធិការមិនចង់រៀបចំរើនក្នុងដំណែលរបស់លោកគ្រូព្រះសភាមុនទេ ឯធម៌វិន័យសេចក្តីប្រតិបត្តិទៀតលោកបាននិយាយនឹងខ្ញុំថា វត្តអារាមមិនទាន់បានឲ្យរៀនសូត្រធម៌វិន័យប្រែប្រួលតាមសម័យដូចគេនៅឡើយទេ ក្រែងតែឥតអំពីសាលាទៅ ។

វត្តកំពង់ហ្លួងនេះ ប្រសិនបើលោកខំប្រឹងខ្នះខ្នែងពាក់ព័ន្ធរៀបចំឲ្យមានរបៀបល្អឡើង មុខជានឹងទៅជាវត្តស្តុកស្តម្ភចំរើនរុងរឿងមួយល្អណាស់ ព្រោះវត្តនេះតាំងនៅចំផ្លូវថ្នល់ពីសាលាស្រុកពញាឮទៅផង ចំកំពង់ផ្លូវស្ទឹងទៅក្រោយម្នាងដែលហៅថាកំពង់ហ្លួងផង មានទំនងគួរឲ្យអ្នករាជការធំ-តូច ឬអ្នកដំណើរទាំងពួងចូលទៅសំណាក់អាស្រ័យម្តងៗ ជាទីសប្បាយណាស់ ប៉ុន្តែសព្វថ្ងៃនេះអ្នករាជការធំ-តូចចូលទៅអង្គរបុរីម្តងៗ ច្រើនតែបង្ហួសទៅសំណាក់អាស្រ័យនៅឯវត្តជ្រយទៅវិញ ព្រោះវត្តនោះសប្បាយជាទីពាប់ចិត្តដល់អ្នករាជការដោយលោកគ្រូតែចៅអធិការវត្តនោះប្រសប់រៀបចំទីវត្តក្តី សាលាវិហារឲ្យមានរបៀបរៀបរយស្អាតល្អ បើមានពួកអ្នករាជការឬអ្នកដំណើរណាចូលទៅលោករមែងធ្វើបដិសណ្ឋារៈតាមសមគួរដល់សមណភាពល្មមឲ្យគេស្រឡាញ់រាប់អានលោក ឯធម៌វិន័យសេចក្តីប្រតិបត្តិក៏នៅជារបៀប

បុណ្ណោះដែរ ប៉ុន្តែកិច្ចការសាមណេរទាំងក្មេងមានរបៀបរៀបរយហើយកោតខ្លាចលោកណាស់ ឯខាងការរៀនសូត្រលោកបានបង្កើតឲ្យមានសាលាបង្រៀនអក្សរខ្មែរទើងបាក់ងមួយហើយ លោកនិយាយនឹងខ្ញុំថានឹងខំប្រឹងបង្កើតឲ្យមានសាលាសំណាក់សម្រាប់អ្នកធំៗ នឹងបង្កើតឲ្យមានគ្រឿងប្រដាប់វិធីហាត់ប្រាណសម្រាប់ពួកយុវជនទាំងក្មេងសាលារៀនទៀតផង ដែលលោកនិយាយទាំងប៉ុន្មានគួរឲ្យចូលចិត្តនឹងគំនិតលោកពេកណាស់ៗ

## អំពីយកទ្រនាប់បល្ល័ង្កទៅភ្នំបាទេពតទៅទៀត

លុះព្រឹកឡើងថ្ងៃ ១៣ សេបតឹមប្រ៍ ខ្ញុំមិនបាននៅមើលអ្នកស្រុកបាត់ដែនប្រគេនចង្ហាន់លោកទេ ព្រោះប្រញាប់នឹងត្រឡប់ទៅយកបល្ល័ង្កនៅភ្នំបាទេពដែលសល់នៅទ្រនាប់ខាងក្រោមមិនទាន់បានយកដែលមានទំហំ ៤ ជ្រុង ៗ ជ្រុង ១ ម៉, ៥០ កំពស់ ០ ម៉, ៣០ គទៅទៀត បំណែកពួកជីវស្តុកម្មក្រសួងសាធារណការតាកែវ ដែលទៅជួយចាត់ចែងអន្ទង់យករូបនឹងបល្ល័ង្កពីថ្ងៃមុនទាំងប៉ុន្មានបានអនុញ្ញាតពីលោកឡឺរេស៊ីដង់តែនឹងព្រះបាទម្ចាស់ហៅហ្វាយ តែត្រូវតាកែវឲ្យឈប់ធ្វើត្រឡប់ទៅតាកែវវិញតាំងពីល្ងាចថ្ងៃ ១២ នៅតែពួកខ្ញុំឲ្យទៅចាត់ការយកតទៅទៀត បំណែកខ្ញុំនឹងលោកអ៊ុក-សេន ក៏នាំពួកគូលីទៅដាក់យកទ្រនាប់បល្ល័ង្កនោះពីលើភ្នំបាទេពមកដោយប្រើរបៀបផ្ទេរពីក្រសួងសាធារណការដែល

ចាត់ការមុន ប៉ុន្តែដោយហេតុថ្មបល្ល័ង្កនោះធ្លាក់ជា ២ កំណាត់ពាក់កណ្ដាល ស្មើគ្នាក៏ស្រាលស្រាយនឹងធ្លាក់ចុះមកជាន់មុនបន្តិចតែ ២ ថ្ងៃប៉ុណ្ណោះ គឺ វេលាម៉ោង ៨ ល្ងាចថ្ងៃ ១៤ សេបតេម្ប៊្រ បានធ្លាក់កន្ទុកនាំទៅទុកនៅ អន្តរពុរីជាស្រេច ប៉ុន្តែធ្លាក់កន្ទុក១ដែលធ្លួលក្រោយទៀតដោយទូក មុនអស់ចំណុះនឹងធ្លាក់ទៅទៀតពុំបាន ឯរបស់ដែលយកពីក្នុងប្រទេសមក ក្នុងវេលានោះគឺៈ បល្ល័ង្កធ្វើជា ២ កំណាត់១ ខាងលើធ្វើជាស្ថានត្រាណ៍ ប្តូរមាយោនី ១, ព្រះពុទ្ធរូបទង់ក្អែន ៣ កំណាត់ ១ ។ ឯការយក បល្ល័ង្កនៅក្នុងប្រទេសនេះពុំមានរឿងអ្វីគួរនិយាយទេ ព្រោះនៅលើក្នុងមាន តែកាបាស់ម្នាក់ជាតិយួនអាយុ ៧០ ឆ្នាំចាំរក្សាហើយមិនជាត្រូវការដោយ បល្ល័ង្កនោះផង ១ ទៀតលើក្នុងនោះជាវត្តពួកកៅដាយដែលចុះចោលយូរ ហើយ ប៉ុន្តែមានរបស់ដែលគួរឲ្យស្តាយនោះដោយក្រសួងសាធារណការចាត់ការដាក់បល្ល័ង្ក (ស្ថានត្រាណ៍) ធ្វើឲ្យខូចខ្ទេចខ្ទី ដល់ជណ្តើរ ដែលឡើងទៅលើក្នុងនោះអស់ជាច្រើន ចាក់ដូចជាមិនគិតដល់ការឡើង ចុះគេទៅទៀត ។

## អំពីយកព្រះពុទ្ធរូបវត្តកំពង់ហ្លួង (អង្គរបុរី)

កាលពីថ្ងៃមុនខ្ញុំបានចូលទៅជួលលោកគ្រូចៅអធិការវត្តកំពង់ហ្លួង នឹងដំណើរលោកមេឃុំផងថា ដល់ថ្ងៃ ១៧ សេបតេម្ប៊្រ ត្រូវនឹងថ្ងៃបុណ្យ

(មានត)

ជាតាភាសិត

ព្រះគ្រូមុនីសោភ័ណ សោម-ឡុង

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(តមកនឹងចប់)

## អំពីការសង្គ្រោះគ្នាក្នុងវេលាមានទុក្ខ

ក្នុងលោកនេះ មនុស្សទាំងអស់ ទោះប្រុសក្តី ស្រីក្តី ក្មេងក្តី ចាស់ក្តី រមែងប្រកបដោយទុក្ខច្រើន សុខតិច កម្រមាននរណានឹងរួចផុតអំពីទុក្ខបានឡើយ កាលបើត្រូវទុក្ខណាទម្ងន់ណាមួយមកបៀតបៀនម្តងៗ ហើយក៏ភ័យភិតតក់ស្លុតញាប់ញ័រ ដូចជាស្លឹកឈើដែលត្រូវខ្យល់បក់ ទំនែសកអំពាវនាវគេឲ្យជួយ នេះព្រោះតែជីវិតមួយនាំឲ្យព្រួយលំបាកដល់គេឯង ប្រសិនបើជនជាគ្នីគ្នាមានទុក្ខធុរៈគ្រោះថ្នាក់ជាទម្ងន់ហើយ ពួកមិត្តសំឡាញ់មិនត្រូវធ្វើគោះគើយព្រងើយទេ ត្រូវតែឈឺឆ្អាលយកចិត្តទុកដាក់ជួយដោះទុក្ខគ្នា ឲ្យបានធាប់ស្រាកទាន់ពេលវេលា ទោះបីរស់ស្លាប់យ៉ាងណា ក៏ត្រូវតែជួយសង្គ្រោះគ្នាឲ្យពេញបន្ទុក កុំមើលបំណាំ កុំរត់ចោលគ្នា ទើបបានហៅថាស្រឡាញ់ កប់អានគ្នីគ្នា ដោយចិត្តស្មោះត្រង់មែនៗ

មួយយ៉ាងទៀត ក្នុងលោកនេះ មានជនខ្លះស្រឡាញ់កប់អានគ្នា ត្រង់តែទ្រព្យរបស់ដែលឲ្យគ្នាទៅវិញទៅមកប៉ុណ្ណោះ ពេលណាគ្នាមានទុក្ខធុរៈជាទម្ងន់ ក៏រេះគេចបាត់ លែងនឹកនា លែងជួយ លែង

រលែកៈ ផងបែបនេះមិនត្រូវយកធ្វើជាមិត្តសំឡាញ់ទេ ។ ការដែល រាប់អានស្រឡាញ់គ្នាដោយស្មោះត្រង់ល្អពិតប្រាកដនោះ មិនមែនបាន តែត្រឹមឲ្យរបស់អ្វីៗ ផល់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ គឺសំដៅយក រហូតដល់គ្នាមានទុក្ខធុរៈគ្រោះថ្នាក់យ៉ាងធ្ងន់ ស៊ើរតែនឹងក្សិណក្ស័យ ជីវិត ហើយបេះគិតគូររកឧបាយជួយដោះទុក្ខគ្នាបាន យ៉ាងនេះឯង ទើប បានហៅថា រាប់អានស្រឡាញ់គ្នា ដោយចិត្តស្មោះត្រង់ពិតមែន រឿង នេះត្រូវគ្នានឹងភាសិតបុរាណដែលលោកបានពោលទុកមកថា "ដើរគ្នា ទាន់គ្រាក្រ សម្បូរល្អទាន់ទុក្ខក្ត" ពាក្យនេះមិនចាំបាច់អធិប្បាយ ទុកឲ្យពួកលោកអ្នកមានបញ្ញាទាំងឡាយពិចារណាមើលចុះ ។ តពីនេះ ទៅ យើងសូមនាំនិទានមកដាក់បន្ទាប់ចុះសេចក្ដី ដើម្បីគ្រាន់បានជា មេគំនិតរបស់អស់លោកអ្នកត្រូវគ្នា ។

## អំពីរឿងសត្វតិរច្ឆានជួយសង្គ្រោះគ្នា

សូមដំណាលរឿងនោះ ដោយសង្ខេប តាមសេចក្ដីក្នុងគម្ពីរមិត-ជាតកទុកនិបាតថា "ក្នុងអតីតកាលកន្លងទៅហើយ គ្រានោះ មានសត្វ ប្រើស ១ អណ្ដើក ១ បក្សីក្អែក ១ សត្វទាំង ៣ នេះជាសំឡាញ់នឹងគ្នា នៅអាស្រ័យក្នុងព្រៃហិមពាន្ត អណ្ដើកនៅក្នុងស្រះ ប្រើសនៅក្នុង ព្រៃក្បែរស្រះនោះ ក្អែកនៅលើចុងឈើក្បែរស្រះនោះដែរ ។ ក្នុងសម័យមួយ មានព្រានម្នាក់ដើរស្វែងរកបាញ់សត្វក្នុងព្រៃ បាន

ប្រទះឃើញស្នាមជើងប្រើសចុះផឹកទឹកស្រះនោះថ្មីៗ ក៏យកអន្ទាក់ព្រ័ត្រ ៣ ធ្នុងទៅដាក់ក្បែរកំពង់ទឹកនោះ លុះដល់បឋមយាមរាត្រី ប្រើសនោះចុះទៅផឹកទឹក ក៏ជាប់ក្នុងអន្ទាក់នោះបម្រាសរើខ្លួនមិនរួច ក៏យកកិតខ្លាំងពេកណាស់ ក៏ស្រែកសម្រែកយ៉ាងខ្លាំងឮដល់ទៅអណ្ដើកនិងរងាវ-កកជាសំឡាញ់ សត្វទាំងពីរនោះក៏បានមកជួបជុំគ្នាគិតរកឧបាយជួយដោះ ឯរងាវកកនិយាយទៅនឹងអណ្ដើកថា "នែអណ្ដើក ឥឡូវប្រើសសំឡាញ់យើងមានគ្រោះថ្នាក់ជាប់អន្ទាក់គេហើយ តើឯងគិតដូចម្ដេច? អណ្ដើកថា "អញតាំងពីកំណើតមិនដែលគិតដូចណាទេវ៉ើយ" រងាវកកថា "បើដូច្នោះ សំឡាញ់ឯងសុខចិត្តធ្វើតាមអញឬទេ" អណ្ដើកថា "បើសំ-ឡាញ់ឯងនិយាយត្រូវ អញធ្វើតាម បើនិយាយខុស អញមិនធ្វើតាមទេ" រងាវកកថា "ឯងតាំងស្ដាប់ចុះ អញប្រាប់ឧបាយឱ្យយ៉ាងស្រួលថាអណ្ដើកឯងមានធ្មេញរឹងមុតគ្រាន់បើ អើចូរឯងទៅខាំខ្សែអន្ទាក់នោះចុះ ឯខ្លួនអញគ្មានធ្មេញទេ មានតែចំពុះ ព្រោះហេតុនោះ ខាងឯធ្វើដំណើរមិនឱ្យព្រានមកដល់ឆាប់ ស្រេចលើរូបអញទាំងអស់ តើឯងយល់ព្រមឬទេ?" អណ្ដើកថា "អើឯងគិតនេះពេញជាត្រូវណាស់ហើយ អញឥតយល់ទាស់ទេ ប៉ុន្តែចប់ក្រែងចួនជាខាំខ្សែអន្ទាក់នោះទៅពុំដាច់ត្រ-ពេក ហើយស្រាប់តែលេចព្រាននោះមកដល់ថែម ខ្លួនអញជាអណ្ដើកមុខជាទីងស្លាប់ក្នុងកណ្ដាប់ដៃព្រាននោះមិនខានឡើយ រងាវកកថា

សំឡាញ់ឯងខំប្រឹងប្រែងទៅចុះ កុំរួញរា ទោះជាមិនសម្រេចដូចប្រាថ្នា ក៏គង់តែការនោះបានធូរខ្លះមិនខាន" អណ្តើកនោះក៏ព្រមធ្វើតាមហើយ ក៏ដើរទៅខាំខ្សែអន្ទាក់នោះ ៗ ចំណែកខាងក្ងោក ក៏ហើរសំដៅទៅផ្ទះព្រាន លុះទៅដល់ក៏ទំលើចុងឈើក្បែរផ្ទះព្រាននោះ ដើម្បីឃ្លាំចាំមើលព្រាននោះគេចេញទៅតាមផ្លូវណា ៗ លុះវេលាបច្ចូសសម័យ ព្រានក៏ភ្ញាក់អំពីដំណេក ក្រោកឡើងលុបមុខមាត់រួចស្រេចបាច់ហើយក៏លូកដៃចាប់ យកលំពែងចេញដើរតាមទ្វារខាងកើតផ្ទះ ដើម្បីនឹងទៅមើលអន្ទាក់ ក្ងោកឃើញហើយក៏ហើរស្ទាក់ឆាបមុខមាត់ព្រាននោះ មិនឲ្យធ្វើដំណើរទៅបានឡើយ ព្រានកើតមួរម៉ៅក្តៅចិត្តក៏និយាយស្តីថា "អាសត្វកាឡកណ្ណី ហេតុអីបានជាឯងហើរមកស្ទាក់មុខអញទំនងជានឹងមានគ្រោះថ្នាក់ដល់អញទេដឹង ឬមួយយ៉ាងណា"? ថាដូច្នោះហើយក៏ត្រឡប់វិលទៅដេកឯផ្ទះវិញ លុះដេកមួយស្របក់ភ្ញាក់ក្រោកឡើងទាញលំពែងកាន់ដើរចេញតាមទ្វារខាងលិចផ្ទះវិញ ឯក្ងោកឃើញហើយក៏ហើរទៅស្ទាក់ឆាបមុខមាត់ព្រាននោះទៀត ព្រានក្តៅចិត្តខ្លាំងពេកដើរទៅមិនរួច ក៏ត្រឡប់វិលទៅដេកឯផ្ទះម្តងទៀត ៗ ឈប់ស្ងៀមប៉ុណ្ណោះ ខ្ញុំនិយាយអំពីអណ្តើកឯណោះវិញ កាលក្រោយក្ងោកមកនោះ អណ្តើកក៏ខំប្រឹងខាំខ្សែអន្ទាក់ដកបទាល់តែឈាមធ្មេញ អស់ដាច់បានតែត្រឹម ២ ធ្នុង នៅសល់ ១ ធ្នុង ក៏ទៀបភ្លឺ អស់កំឡាំងនឹងខំប្រឹងទៀត

ទៅទៀតមិនបាន លើខ្នងប្រាណខ្ទាំងពកក៏ក្រាបដេកក្បែរអន្ទាក់នោះ ឯង ៗ លុះដល់វេលាព្រះអាទិត្យរះភ្លឺច្បាស់មេឃា ព្រានភ្ញាក់ក្រោក ឡើងមិញាប្រញាប់យកលំពែងកាន់ដើរចេញអំពីផ្ទះ ប្រាថ្នាទឹងទៅ មើលអន្ទាក់មួងៈទៀត ៗ វេលានោះរនាវកកក៏ឈប់ហើរទៅឆាបមុខ មាត់ព្រានទៀតហើយ ព្រោះគិតថាពេលថ្ងៃណេះ ល្មមអណ្តើកខាំ ខ្សែអន្ទាក់ដាច់អស់ហើយ ក៏ហើរទៅមុនព្រានដោយឆាប់ប្រញាប់ លុះ ទៅដល់ហើយទើបសួរទៅអណ្តើកថា រុយសំឡាញ់ ឯងខាំខ្សែអន្ទាក់ ដាច់អស់ហើយឬនៅ មិនទាន់បានដាច់អស់ទេ សំឡាញ់ដាច់បានតែ ២ ធ្នង់ នៅសល់ ១ធ្នង់ទៀត ឥឡូវឈាមហូរចេញអំពីធ្មេញអំពីមាត់អញ ៗ ខំប្រឹងខាំតទៅទៀតមិនបានទេ ណាមួយនឿយព្រួយអស់កំឡាំងពេក ណាស់ អញឈប់សម្រាកបន្តិចសិន សំឡាញ់ឯងឈប់សម្រាកឯណា ក៏បាន មិនបានទេ ព្រោះព្រានគាត់មកកាន់តែជិតដល់ហើយ ក្រែងក់ ស្លាប់ទាំងអស់គ្នាហ្នឹងទៅ ស្លាប់ក៏ស្លាប់ចុះមិនដឹងធ្វើម៉េចទេ ឲ្យអញខាំ ខ្សែអន្ទាក់ទៀត ឯណាក៏បាន បើគ្នាឈាមធ្មេញអស់ទៅហើយ បើ អាសំឡាញ់ឯងគ្រាន់បើ មុខក៏មិនទៅលបន្តិចមើល ៗ សត្វទាំងពីរ កំពុងតែនិយាយជជែកគ្នា មិនយូប៉ុន្មាន ក៏ស្រាប់តែលេចព្រាននោះ ទៅដល់ ព្រាននោះក្រឡេកមើលទៅឃើញប្រើសជាប់អន្ទាក់ដូច្នោះ ក៏កាន់លំពែងស្ទុះទៅប្រុងនឹងចាក់ ប្រើសភ័យពេកណាស់ក៏ប្រឹងលើក

ជើងក្អែក ខ្សែអន្ទាក់ក៏ដាច់អស់ឫពោរពេញ ហើយបោលវេះគេចចូលទៅក្នុងព្រៃ ព្រានក៏នឹកតូចចិត្តពេក ក្រឡេកមើលទៅឃើញអណ្ដើកជើកក្បែរទំនោះ ក៏ស្ទុះទៅចាប់រើសដាក់ក្នុងស្បោងហើយយកទៅពាក់លើងគល់ឈើ ឯប្រើសនោះងាកមើលមកក្រោយវិញ ឃើញព្រានកំពុងតែចាប់អណ្ដើកដាក់ក្នុងស្បោង យកទៅពាក់លើងគល់ឈើដូច្នោះ ក៏មានចិត្តអាណិតពេកណាស់ គិតថាឲសំឡាញ់អញ កាលអញមានទុក្ខទោស បេះជួយដោះទុក្ខអញបាន ឥឡូវសំឡាញ់អញមានទុក្ខត្រូវតែអញជួយដោះទុក្ខគេវិញ គិតដូច្នោះហើយក៏ធ្វើហាក់ជាបោលគេចៗ ព្រានក៏រត់ដេញតាមប្រើសៗ បោលចូលក្នុងព្រៃជ្រៅ ព្រានតាមជ្រុលទៅខាងមុខ ប្រើសវេះគេចមកខាងក្រោយបោលវិលត្រឡប់មកវង ស្បោងនោះដាច់ធ្លុះធ្លាយធ្លាក់អណ្ដើកមកដល់ដី ហើយនាំយកអណ្ដើកចេះវេះគេចចូលទៅក្នុងព្រៃបាត់ លុះព្រាននោះតាមរកប្រើសមិនឃើញ ក៏ត្រឡប់វិលមកវិញ ដល់មកកន្លែងហើយក្រឡេកមើលទៅស្បោងលើគល់ឈើ ក៏ធ្លាក់ដាច់ដាចអស់ ចាំងអណ្ដើកក៏បាត់រកមើលមិនឃើញ ក៏កើតទោមនស្សអន់ចិត្តវិលត្រឡប់ទៅផ្ទះវិញ ។

គ្រាក្រោយមក សត្វទាំង ៣ ក៏បានមកជួបជុំគ្នា ស្រឡាញ់រាប់អានគ្នា គ្រាតែអស់ជីវិតរៀងខ្លួន ។

ចប់រឿងការសង្គ្រោះគ្នា ប៉ុណ្ណេះ ។

# ប្រវត្តិព្រះពុទ្ធ ៧ ព្រះអង្គ[១]

## ១- ព្រះពុទ្ធវិបស្សី

កប់អំពីកប្បនេះថយក្រោយទៅបាន ៩១ កប្ប ព្រះពុទ្ធវិបស្សី ទ្រង់បានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាកោណ្ឌញ្ញគោត្រ មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមបាដលិព្រឹក្ស (ដើមផ្ទៀង) មានគូសាវកឈ្មោះខណ្ឌ ១ តិស្ស ១ មានសាវកសន្និបាត ៣ ដង គឺ សាវកសន្និបាតមានភិក្ខុ ៦ លាន ៨ សែនរូបមក សាវកសន្និបាតមាន ភិក្ខុ ១ សែនរូបមក សាវកសន្និបាតមានភិក្ខុ ៨ ម៉ឺនរូបមក សាវកសន្និ- បាតទាំង ៣ ដងនេះសុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះ អសោកជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតា ទ្រង់ព្រះនាមពន្ធុមតី ជាព្រះជនេត្តី (ព្រះមាតាបង្កើត) នគរឈ្មោះពន្ធុមតី ។

## ២- ព្រះពុទ្ធសិខី

កប់អំពីកប្បនេះថយក្រោយទៅបាន ៣១ កប្ប ព្រះពុទ្ធសិខី ទ្រង់បានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាកោណ្ឌញ្ញគោត្រ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមបុណ្ឌរិកព្រឹក្ស (ដើម ស្វាយស) មានគូសាវកឈ្មោះអភិភូ ១ សម្ភវៈ ១ មានសាវកសន្និបាត ៣ ដង គឺមានភិក្ខុ ១ សែនរូបមក មានភិក្ខុ ៨ ម៉ឺនរូបមក មានភិក្ខុ ៧ ម៉ឺនរូបមក សាវកសន្និបាតទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រព

---

១ ស្រង់មកអំពីសៀវភៅព្រះត្រៃបិដកខ្មែរ ភាគទី ១៦ ត្រង់មហាបទានសូត្រទំព័រ ២៨... ។

ទាំងអស់ មានភិក្ខុឈ្មោះខេមង្ករៈជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមអរុណ ព្រះមាតាទ្រង់ព្រះនាមបភាវតី ជាព្រះជនេត្តី នគរឈ្មោះអរុណវតី ។

## ៣- ព្រះពុទ្ធវេស្សភូ

រាប់អំពីកប្បនេះថយក្រោយទៅបាន ៣១ កប្ប ព្រះពុទ្ធវេស្សភូទ្រង់បានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាកោណ្ឌញ្ញគោត្រ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមសាលព្រឹក្ស (ដើមរាំងភ្នំ) មានគូសាវកឈ្មោះសោណៈ ១ ឧត្តរៈ ១ មានសាវកសន្និបាត ៣ ដង គឺមានភិក្ខុ ៨ ម៉ឺនរូបម្ដង មានភិក្ខុ ៧ ម៉ឺនរូបម្ដង មានភិក្ខុ ៦ ម៉ឺនរូបម្ដង សាវកសន្និបាតទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះឧបសន្តៈ ជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមសុប្បតីតៈ ព្រះមាតាទ្រង់ព្រះនាមយសវតី ជាព្រះជនេត្តី នគរឈ្មោះអនោមៈ ។

## ៤- ព្រះពុទ្ធកកុសន្ធ

ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធកកុសន្ធបានត្រាស់ក្នុងលោកព្រះអង្គជាព្រាហ្មណជាតិ ជាកស្សបគោត្រ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមសិរីសព្រឹក្ស (ដើមចែស) មានគូសាវកឈ្មោះវិធុរៈ ១ សញ្ជីវៈ ១ មានសាវកសន្និបាតតែម្ដង មានភិក្ខុ ៤ ម៉ឺនរូប សុទ្ធតែជា

ព្រះខីណាស្រពទាំងអស់ មានព្រះភិក្ខុឈ្មោះវុឌ្ឍិជៈជាឧបដ្ឋាក ព្រះបិតាជាព្រាហ្មណ៍នាមអគ្គិទត្ត ព្រះមាតាជាព្រាហ្មណីនាមវិសាខា ជាព្រះជនេត្តិសម័យនោះ មានព្រះរាជាព្រះនាមខេមៈ នគរឈ្មោះខេមវតី ។

## ៥- ព្រះពុទ្ធកោនាគមន

ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធកោនាគមនបានត្រាស់ក្នុងលោក ព្រះអង្គជាព្រាហ្មណជាតិ ជាកស្សបគោត្រ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមឧទុម្ពរព្រឹក្ស (ដើមល្វា) មានគូសាវកឈ្មោះភិយ្យោសៈ១ ឧត្តរៈ១ មានសាវកសន្និបាតតែម្តង មានភិក្ខុ ៣ ម៉ឺនរូប សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះសោត្ថិជៈ ជាឧបដ្ឋាក ព្រះបិតាជាព្រាហ្មណ៍នាមយញ្ញទត្ត ព្រះមាតាជាព្រាហ្មណីនាមឧត្តរា ជាព្រះជនេត្តិសម័យនោះ មានព្រះរាជាព្រះនាមសោភៈ នគរឈ្មោះសោភវតី ។

## ៦- ព្រះពុទ្ធកស្សប

ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធកស្សបបានត្រាស់ក្នុងលោក ព្រះអង្គជាព្រាហ្មណជាតិ ជាកស្សបគោត្រ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមនិគ្រោធព្រឹក្ស (ដើមជ្រៃ) មានគូសាវកឈ្មោះតិស្សៈ១ ភារទ្វាជៈ១ មានសាវកសន្និបាតតែម្តង មានភិក្ខុ ២ ម៉ឺនរូប សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះសព្វមិត្តជាឧបដ្ឋាក ព្រះបិតាជា

ព្រាហ្មណ៍នាមព្រហ្មទត្ត ព្រះមាតាជាព្រាហ្មណីនាមធនវតី ជាព្រះជនេត្តី សម័យនោះ មានព្រះរាជាព្រះនាមកិកី នគរឈ្មោះពារាណសី ។

## ៣- ព្រះពុទ្ធគោតម

ក្នុងកប្បនេះ ព្រះពុទ្ធគោតមបានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាគោតមគោត្រ មានព្រះជន្មាយុ ៨០ ឆ្នាំ ត្រាស់ក្រោមដើមអស្សត្ថព្រឹក្ស (ដើមពោធិ៍ព្រាយ) មានគូសាវកឈ្មោះសារីបុត្ត ១ មោគ្គល្លាន ១ មានសាវកសន្និបាតតែម្តង មានភិក្ខុ ១ ពាន់ ២ រយ ៥០ រូប សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះអានន្ទជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមសុទ្ធោទនៈ ព្រះមាតាទ្រង់ព្រះនាមមហាមាយា ជាព្រះជនេត្តី ព្រះនគរឈ្មោះកបិលវត្ថុ ។

ចប់

# អរិយសច្ចជាពុទ្ធភាសិត

## បទទី ១

## សត្វលោកនឹងចតុរារិយសច្ច

បើមិនដឹងច្បាស់នូវអរិយសច្ច នឹងធ្វើនូវទីបំផុតទុក្ខមិនបាន ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលណាមួយនិយាយថា: "ខ្ញុំមិនដឹងច្បាស់នូវសេចក្ដីពិតដ៏ប្រសើរគឺទុក្ខ, នូវសេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ, នូវសេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ, នូវសេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខតាមសេចក្ដីពិតទេ, ប៉ុន្តែខ្ញុំនឹងធ្វើនូវទីបំផុតនៃសេចក្ដីទុក្ខ ដោយប្រពៃឲ្យបាន" សេចក្ដីនេះមិនមែនជាឋានៈ គឺមិនត្រឹមត្រូវតាមគន្លងធម៌ទេ ។ សេចក្ដីនេះគួរនាដូចជាបុគ្គលណាមួយនិយាយថា: "ខ្ញុំមិនបាច់ធ្វើនូវគ្រឿងផ្ទះខាងក្រោម (ដូចសសរ រត បន្ទល់ជាដើម) ទុកជាមុនសិនទេ ប៉ុន្តែខ្ញុំនឹងសង់គ្រឿងផ្ទះខាងលើបាន" សេចក្ដីនេះមិនមែនជាឋានៈ គឺមិនត្រឹមត្រូវតាមទំនងយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ! រីឯបុគ្គលណាមួយនិយាយថា: "ខ្ញុំមិនដឹងច្បាស់នូវសេចក្ដីពិតដ៏ប្រសើរគឺទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ តាមសេចក្ដីពិតទេ ប៉ុន្តែ

ខ្ញុំនឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ដោយប្រពៃបាន សេចក្តីនេះមិនមែនជាឋានៈ គឺមិនត្រឹមត្រូវតាមគន្លងធម៌យ៉ាងនោះដែរ" ៗ

ម្នាលភិក្ខុទាំងឡាយ! បុគ្គលណាមួយនិយាយថា: "ខ្ញុំគប្បីដឹងច្បាស់នូវសេចក្តីពិតដ៏ប្រសើរគឺទុក្ខ, នូវសេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ, នូវសេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ, នូវសេចក្តីពិតដ៏ប្រសើរគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ, តាមសេចក្តីពិត, ទើបខ្ញុំនឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ដោយប្រពៃបាន" សេចក្តីនេះជាឋានៈ គឺត្រឹមត្រូវតាមគន្លងធម៌ ៗ សេចក្តីនេះឧបមាដូចជាបុគ្គលណាមួយនិយាយថា: "ខ្ញុំគប្បីធ្វើគ្រឿងផ្ទះខាងក្រោមទុកមុនសិន ទើបសង់គ្រឿងផ្ទះខាងលើ" សេចក្តីនេះជាឋានៈ គឺត្រឹមត្រូវតាមគន្លងធម៌យ៉ាងណាមិញ ៗ ម្នាលភិក្ខុទាំងឡាយ! រីឯបុគ្គលណាមួយនិយាយថា: "ខ្ញុំគប្បីដឹងច្បាស់នូវសេចក្តីពិតដ៏ប្រសើរគឺទុក្ខ នូវសេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ នូវសេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ នូវសេចក្តីពិតដ៏ប្រសើរគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ តាមសេចក្តីពិតទុកជាមុនសិន ទើបខ្ញុំគប្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ដោយប្រពៃបាន សេចក្តីនេះជាឋានៈ គឺត្រឹមត្រូវតាមគន្លងធម៌ យ៉ាងនោះដែរ" ៗ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាម ដើម្បីឲ្យដឹងថា:

"នេះទុក្ខ ? នេះហេតុប្រជុំកើតឡើងនៃទុក្ខ ? នេះធម៌ជាគ្រឿងរំលត់ទុក្ខ ? នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ? ដូច្នេះចុះ ។

មហាវារៈ សំ. ១៩-៥៦៤-១៧៣៤

ព្រោះមិនដឹងច្បាស់នូវសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការ បានជាសត្វលោកអន្ទោលទៅក្នុងពលវដ្ដសង្សារមិនឈប់ ។

ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះហើយត្រាស់ថា:

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយក្ដី តថាគតក្ដី ដែលចេះតែត្រាច់រង្គាត់ទៅ ចេះតែអន្ទោលចេរវិលវិលទៅ (ក្នុងពលសង្សារវដ្ដ) អស់កាលយូរដល់ម្ល៉េះ ព្រោះតែមិនដឹងច្បាស់ មិនឈ្វេងយល់នូវអរិយសច្ចសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការ ។ ចុះអរិយសច្ច សេចក្ដីពិតដ៏ប្រសើរ៤ប្រការ ដែលអ្នកទាំងឡាយនិងតថាគត មិនដឹងច្បាស់ មិនឈ្វេងយល់ នុះតើដូចម្ដេច ? ។ ម្នាលភិក្ខុទាំងឡាយ ? ព្រោះអ្នកទាំងឡាយក្ដី តថាគតក្ដី មិនដឹងច្បាស់ មិនឈ្វេងយល់ នូវសេចក្ដីពិតដ៏ប្រសើរគឺទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរ គឺធម៌ជាគ្រឿងរំលត់ទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ បានជាចេះតែត្រាច់រង្គាត់ទៅ ចេះតែអន្ទោលចេរវិលវិលទៅ (ក្នុងពលវដ្ដសង្សារ)

អស់កាលយូរដល់ម៉្លេះដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ! អរិយសច្ច សេចក្តីពិតដ៏ប្រសើរទាំងឡាយនោះ តថាគតបានត្រាស់ដឹងហើយ បានឈ្វេងយល់សព្វហើយ ។ ភវតណ្ហា សេចក្តីប្រាថ្នាក្នុងភព តថាគតបានកាត់ផ្តាច់ផ្តិលអស់ហើយ កិរិយានាំទៅកាន់ភពថ្មីទៀតអស់ ប៉ុណ្ណឹងហើយ ឥឡូវនេះ តថាគតមិនមានភពថ្មីទៀតឡើយ ។

មហាវារៈ សំ. ១៩-៤០-១៦៩៨

ព្រះតថាគតមិនត្រាស់ដឹងក្នុងលោកត្រឹមណា សេចក្តីងងឹតសូន្យសុង នៃលោកនៅមានត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ! ព្រះចន្ទនិងព្រះអាទិត្យមិនកើតឡើងក្នុង លោកអស់កាលត្រឹមណា សេចក្តីប្រាកដនៃពន្លឺភ្លឺស្វាងដ៏ក្រៃលែង ក៏ មិនមានអស់កាលត្រឹមនោះដែរ ! ក្នុងកាលនោះមានតែសេចក្តីងងឹត អ័ព្ទសូន្យសុង ដូចសេចក្តីងងឹតនៃបុគ្គលភ្លេកខ្វាក់ ថ្ងៃ ខែ បក្ស រដូវនិង ឆ្នាំ ក៏មិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ! កាលណាព្រះចន្ទ និងព្រះអាទិត្យកើតឡើងក្នុងលោក កាលនោះ សេចក្តីប្រាកដឡើង នៃពន្លឺភ្លឺស្វាងរុងរឿងដ៏ក្រៃលែងទើបកើតប្រាកដឡើង, សេចក្តីងងឹត អ័ព្ទសូន្យសុងដូចសេចក្តីងងឹតនៃបុគ្គលភ្លេកខ្វាក់ ក៏មិនមានក្នុងកាល នោះ ថ្ងៃ ខែ បក្ស រដូវ ឆ្នាំ ក៏បានប្រាកដឡើង; សេចក្តីនេះមាន ឧបមាយ៉ាងណា ។

ម្នាលភិក្ខុទាំងឡាយ! សេចក្ដីនេះមានឧបមេយ្យដូចគ្នាដែរថា ដរាបអស់កាលត្រឹមណា ព្រះតថាគតអរហំសម្មាសម្ពុទ្ធមិនត្រាស់ដឹងឡើងក្នុងលោក, អស់កាលត្រឹមនោះ សេចក្ដីប្រាកដនៃពន្លឺភ្លឺស្វាងរុងរឿងដ៏ក្រៃលែងក៏មិនកើតឡើង, ក្នុងកាលនោះមានតែសេចក្ដីងងឹតអ័ព្ទសូន្យសុន្យដូចសេចក្ដីងងឹតនៃបុគ្គលភ្នែកខ្វាក់ មិនមានការប្រាប់គ្នា, ការសំ-ដែងពន្យល់, សេចក្ដីបញ្ញត្តិ, ការតាំងទុក, ការបើកបង្ហាញ, ការចែករំលែកឲ្យមានសេចក្ដីរាក់. នូវសេចក្ដីពិតដ៏ប្រសើរទាំងឡាយ ៤ ប្រការនេះឡើយ, ម្នាលភិក្ខុទាំងឡាយ កាលណា ព្រះតថាគតអរហំសម្មា-សម្ពុទ្ធត្រាស់ដឹងឡើងក្នុងលោក សេចក្ដីប្រាកដនៃពន្លឺភ្លឺស្វាងរុងរឿងដ៏ក្រៃលែងក៏កើតឡើង, ក្នុងកាលនោះ មិនមានសេចក្ដីងងឹតអ័ព្ទសូន្យសុន្យ ដូចសេចក្ដីងងឹតនៃបុគ្គលភ្នែកខ្វាក់, ក្នុងកាលនោះ ទើបមានការប្រាប់គ្នា, សំដែងពន្យល់, សេចក្ដីបញ្ញត្តិ, ការតាំងទុក, ការបើកបង្ហាញ ការចែករំលែកឲ្យមានសេចក្ដីរាក់ នូវសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការនេះឡើង ។

មហាវារៈសំ. ១៩-៥៥៣-១៧២១

### អរិយសច្ច ៤ ជាធម៌មិនប្រែប្រួល

ម្នាលភិក្ខុទាំងឡាយ! មានធម្មជាតិ ៤ យ៉ាង នៅតែទៀងដដែល មិនផ្លាស់ប្ដូរពីដដែល មិនប្រែប្រួលទៅជារបស់ដទៃ ។ ធម្មជាតិ ៤

យ៉ាងនោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! ធម្មជាតិទាំង ៤ យ៉ាងនោះគឺ: ទុក្ខនេះ ១, ហេតុប្រជុំកើតឡើងនៃទុក្ខនេះ ១ ធម៌ជាគ្រឿងរំលត់ទុក្ខនេះ ១ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខនេះ ១ នៅតែនឹងដដែល មិនផ្លាស់ប្តូរពីដដែល មិនចេះប្លែកខុសទៅជារូបដទៃ ៗ ម្នាលភិក្ខុទាំងឡាយ! ធម្មជាតិទាំងឡាយ ៤ ប្រការនេះ នៅតែនឹងដដែល មិនផ្លាស់ប្តូរពីដដែល មិនចេះប្លែកខុសទៅជារូបដទៃទេ ៗ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាមដើម្បីឲ្យដឹងថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" តែប៉ុណ្ណោះឯងចុះ ៗ

ឧហារៈ សំ.១៩-៥៣៩-១៦៩៣

## សេចក្តីសុខដែលសត្វលោកគួរខ្លាច និងមិនគួរខ្លាច

ពាក្យនេះតថាគតបានពោលរួចហើយថា: "បុគ្គលគប្បីចេះវិនិច្ឆ័យសេចក្តីសុខ លុះចេះវិនិច្ឆ័យសេចក្តីសុខហើយ គប្បីប្រកបសេចក្តីសុខខាងក្នុងសន្តានឲ្យរឿយៗទៅ ៗ" ពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! កាមគុណមាន ៥ យ៉ាងគឺ: រូបដែលបុគ្គលគប្បីដឹងដោយភ្នែក សំឡេងដែលបុគ្គលគប្បីដឹងដោយត្រចៀក ក្លិនដែលបុគ្គលគប្បីដឹងដោយច្រមុះ

រសដែលបុគ្គលគប្បីដឹងដោយអណ្ដាត ផោដ្ឋព្វៈដែលបុគ្គលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ប្រកបដោយកាម ឈ្ងក់ក្នុងសេចក្ដីត្រេកអរ ។ ម្នាលភិក្ខុទាំងឡាយ! សេចក្ដីសុខនិងសោមនស្សឯណាដែលកើតឡើង ព្រោះអាស្រ័យនូវកាមគុណទាំង ៥ នេះ សេចក្ដីសុខសោមនស្សនោះ តថាគតហៅថាជាសុខកាមគុណ ជាសេចក្ដីសុខរបស់បុថុជ្ជន ជាសេចក្ដីសុខនាំងមេថុនធម្ម មិនមែនសេចក្ដីដ៏ប្រសើរទេ, តថាគតពោលថា: "សេចក្ដីសុខបែបនេះបុគ្គលមិនគួរសេពមិនគួរចំរើន មិនគប្បីធ្វើឲ្យច្រើន ព្រោះជាសុខគួរខ្លាច" ។

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានសម្រេចបឋមជ្ឈាន . . . ទុតិយជ្ឈាន . . . តតិយជ្ឈាន . . . ចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះតថាគតហៅថា នេក្ខមសុខ សេចក្ដីសុខកើតអំពីការចេញចាកកាម, បវិវេកសុខ សេចក្ដីសុខកើតអំពីសេចក្ដីស្ងាត់ចាកកាមនិងអកុសលធម៌, ឧបសមសុខ សេចក្ដីសុខកើតអំពីរម្ងាប់នីវរណធម៌ជាដើម និងសម្ពោធិសុខ សេចក្ដីសុខប្រព្រឹត្តទៅដើម្បីត្រាស់ដឹងមគ្គផលនិព្វាន តថាគតពោលថា: "សេចក្ដី

សុខបែបនេះ បុគ្គលគួរគប្បីសេពទៅ គួរធ្វើឲ្យចំរើន គួរធ្វើឲ្យច្រើនឡើង ព្រោះជាសុខមិនគួរខ្លាចទេ" ។

ពាក្យឯណាដែលតថាគតពោលរួចហើយថា៖ "បុគ្គលគប្បីបេះវិនិច្ឆ័យ សេចក្ដីសុខ លុះបេះវិនិច្ឆ័យសេចក្ដីសុខហើយ គប្បីប្រកបសេចក្ដីសុខប៉ែកខាងក្នុងសន្ដានឲ្យរឿយៗទៅ", ពាក្យនេះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

ឧបរិ. ម. អរណវិភង្គសូត្រ ២៨-១៥៦-១៣៤.

សេចក្ដីមាំមួនរបស់ស្រុកទេសមិនមែនជាភាពនៃសេចក្ដីប្រសើរ

ម្នាលភិក្ខុទាំងឡាយ ក្នុងពួកជនបទខាងត្បូងទាំងឡាយ មានជនបទឈ្មោះគោនៈ, នៅក្នុងជនបទនោះ មានស្រូវ មានចំក មានគ្រឿងបន្ថែម មានគ្រឿងបរិភោគ មានរបស់គួរភ្លក់ មានរបស់គួរផឹក មានរបាំ មានចំរៀង មានគ្រឿងប្រគំតូរ្យតន្ត្រី ។ ម្នាលភិក្ខុទាំងឡាយ! ជនបទឈ្មោះគោនៈជាប្រទេសមានទ្រព្យសម្បត្តិមែន មិនមែនតថាគតនិយាយថាមិនមានទេ តែថាជនបទឈ្មោះគោនៈនោះជាប្រទេសថោកទាប ជារបស់អ្នកស្រុក គួរដល់បុថុជ្ជន មិនប្រសើរ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ

ដើម្បីសេចក្តីរលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹង ដើម្បីត្រាស់ដឹង និងដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ! តថាគតនឹងសំដែង ធម៌នេះដ៏ប្រសើរ ដែលប្រព្រឹត្តទៅដើម្បីនឿយណាយតែម្យ៉ាងចំណែក ដើម្បីប្រាសចាកតម្រេក: ដើម្បីរំលត់ទុក្ខ ដើម្បីសេចក្តីរម្ងាប់ទុក្ខ ដើម្បីសេចក្តីដឹង ដើម្បីត្រាស់ដឹង នឹងដើម្បីព្រះនិព្វាន (ព្រោះថា) សត្វទាំងឡាយដែលមានជាតិជាធម្មតា បានអាស្រ័យធម៌នេះនោះហើយ ក៏រួចស្រឡះអំពីជាតិបាន, សត្វទាំង- ឡាយដែលមានជរាជាធម្មតា បានអាស្រ័យនូវធម៌នេះនោះហើយ នឹងរួចស្រឡះអំពីជរាធម៌បាន, សត្វទាំងឡាយ ដែលមានព្យាធិជាធម្មតា បានអាស្រ័យនូវធម៌នេះនោះហើយ ក៏រួចស្រឡះអំពីព្យាធិបាន, សត្វទាំងឡាយ ដែលមានមរណៈជាធម្មតា បានអាស្រ័យនូវធម៌នេះនោះហើយ ក៏រួចស្រឡះអំពីមរណៈបាន, សត្វទាំងឡាយដែលមានសេចក្តីសោក យំសង្រេងសង្រៃ ទុក្ខលំបាក ទោមនស្សតូចចិត្ត តានតឹងក្នុងចិត្តជាធម្មតា បានអាស្រ័យនូវធម៌នេះនោះហើយ ក៏រួចស្រឡះអំពីសេចក្តីសោក យំសង្រេងសង្រៃ ទុក្ខលំបាក ទោមនស្សតូចចិត្ត តានតឹងក្នុងចិត្តបាន ។ ភិក្ខុទាំងឡាយចូរស្តាប់ពាក្យនេះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ (មានត)